ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

## គ.ក.ប/គ.ក.រ

## សម្រាប់
## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
## នីតិកាលទី៦ ឆ្នាំ២០១៨

*(ថ្ងៃអាទិត្យ ទី២៩ ខែកក្កដា ឆ្នាំ២០១៨)*

# មាតិកា


**គោលបំណង** ........ ១

I. **ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត** ........ ២

១. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........ ២

២.បរិវេណខាងក្នុង ........ ២

៣.បរិវេណខាងក្រៅ ........ ២

៤. ឆ្មាំការសន្តិសុខបោះឆ្នោត ........ ២

៥.វិធានការសន្តិសុខ ........ ៣

II. **គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ)** ........ ៦

១. សមាសភាព គ.ក.ប ........ ៦

២.ការទទួលខុសត្រូវ និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ ........ ៦

III. **ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប សម្ភារ ឯកសារ និងទីតាំងការិយាល័យបោះឆ្នោត (នៅថ្ងៃសៅរ៍ ១ថ្ងៃមុនថ្ងៃបោះឆ្នោត)** ........ ៦

១. ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប ........ ៦

២.ការទទួល និងការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........ ៧

ក. សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែល គ.ក.ប ត្រូវទទួល ........ ៧

ខ. ការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........ ៩

គ. ការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ និងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ........ ១០

ឃ. ការរក្សាការពារសម្ភារ ឯកសារបោះឆ្នោត ........ ១០

៣.ការរៀបចំការិយាល័យបោះឆ្នោត ........ ១១

៤.ការប្រើប្រាស់បញ្ជីបោះឆ្នោតផ្លូវការ ........ ១២

IV. **ការប្រព្រឹត្តទៅនៃការបោះឆ្នោត** ........ ១២

១. ការរៀបចំសម្ភារ ឯកសារបោះឆ្នោត និងការពន្យល់ណែនាំជារួមដល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន ........ ១២

ក. ការរៀបចំសម្ភារ ឯកសារបោះឆ្នោត ........ ១២

ខ. ការពន្យល់ណែនាំជារួមដល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន ........ ១៣

២. ភារកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:០០ នាទីដល់ម៉ោង ៦:៣០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត ........ ១៤

៣. ភារកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:៣០ នាទីដល់ម៉ោង ៧:០០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត ........ ១៥

ក. ការត្រួតពិនិត្យកញ្ចប់សន្លឹកឆ្នោត ........ ១៦

ខ. ការបង្ហាញត្រាសម្ងាត់ ........ ១៦

៤. ការបោះឆ្នោត និងឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត ......................................... ១៧
៥. រយៈពេលបោះឆ្នោត៖ ចាប់ពីម៉ោង ៧:០០ នាទីព្រឹកដល់ម៉ោង ៣:០០ នាទីរសៀល ............................ ១៨
៦. ការងាររបស់ប្រធាន គ.ក.ប ក្នុងពេលមានករណីផ្សេងៗកើតឡើងនៅពេលបោះឆ្នោត........................ ២៣
ក. ករណីអ្នកបោះឆ្នោតមានម្រាមដៃប្រឡាក់ស្នាមទឹកខ្មៅលុបមិនជ្រះ ឬរូបថតមិនដូចគ្នា ឈ្មោះ ឬទិន្នន័យមិនដូចគ្នា ........................................................................................... ២៣
ខ. ករណីលេខាធិការរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតមិនឃើញ ................................. ២៣
គ. ករណីអ្នកបោះឆ្នោតណាម្នាក់មានបំណងសែកសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និង សន្លឹកឆ្នោតលើសពី ១សន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញពី ការិយាល័យបោះឆ្នោត .................................................................................................. ២៣
ឃ. ករណីអ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង..................... ២៤
ង. ករណីអ្នកបោះឆ្នោតជាជនពិការភ្នែកទាំងសងខាង ហើយមានបំណងចង់បោះឆ្នោតដោយខ្លួនឯង..... ២៤
ច. ករណីអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប៉ុនប៉ងចង់ឃើញការគូសសញ្ញានៅលើសន្លឹកឆ្នោត របស់អ្នកបោះឆ្នោត ...................................................................................................... ២៦
ឆ. ករណីអ្នកបោះឆ្នោតធ្វើឱ្យខូចសន្លឹកឆ្នោត ឬធ្វើឱ្យរហែក ឬធ្វើឱ្យប្រឡាក់ដោយអចេតនា ឬដែល បានគូសសញ្ញាលើសន្លឹកឆ្នោតរួចហើយ តែបានប្តូរចិត្តវិញ...................................................... ២៦
ជ. ករណីមានការជំទាស់ ឬតវ៉ាពីភ្នាក់ងារគណបក្សនយោបាយណាម្នាក់ក្នុងពេលបោះឆ្នោត............... ២៧
ឈ. ករណីមានអ្នកបោះឆ្នោតណាម្នាក់រំខានដល់កិច្ចប្រតិបត្តិការបោះឆ្នោត ទោះបីគាត់ស្ថិតនៅក្នុង ការិយាល័យបោះឆ្នោត ឬកំពុងឈរតម្រង់ជួរនៅខាងក្រៅការិយាល័យក្តី ................................... ២៧
ញ. ករណីកិច្ចប្រតិបត្តិការបោះឆ្នោតត្រូវបាននាំខានដល់កម្រិតដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោត បន្តទៀតបាន ............................................................................................................ ២៨
ដ. ករណីការបោះឆ្នោតឈានដល់ពេលបញ្ចប់នៅម៉ោង ៣:០០ នាទីរសៀល ហើយនៅតែមានអ្នកបោះឆ្នោត ស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត ........................................................ ២៨
៧. ការបិទការិយាល័យបោះឆ្នោតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ............. ២៩
ក. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន កើតមាននៅមុនថ្ងៃបោះឆ្នោត ............... ២៩
ខ. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន កើតមាននៅក្នុងថ្ងៃបោះឆ្នោត នៅមុនពេល ឬក្នុងពេលដំណើរការបោះឆ្នោត ...................................................................................... ២៩
គ. ករណីមានការិយាល័យបោះឆ្នោតមិនត្រូវបានបើក ឬត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ......................................................................... ២៩
ឃ. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន កើតមានឡើងនៅក្រោយពេលបិទការ បោះឆ្នោតដែលពេលនោះ ទ.១១០១ ត្រូវបានធ្វើរួចរាល់ ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោត បោះរួចហើយនៅខាងក្នុង រួមទាំងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅរក្សាបានល្អ ...................... ៣០

ង. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន កើតមានឡើងនៅក្រោយពេលបិទការបោះឆ្នោត ហើយ ទ.១១០១ ត្រូវបានធ្វើរួចរាល់ ប៉ុន្តែហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចហើយនៅខាងក្នុង រួមទាំងសម្ភារ ឯកសារ ត្រូវបានបំផ្លាញ ឬខូច ...... ៣០

V. **ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត** ...... ៣១

១. ការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច(បើមាន) ...... ៣១

២. រូបមន្តផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ...... ៣២

៣. កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងការប្រើប្រាស់ ...... ៣២

៤. ការរៀបចំដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រដោយឡែកពីគ្នា រួចដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព «ក» (មិនទាន់បិទផ្ទិតការសុវត្ថិភាព) ...... ៣៣

៥. ការរៀបចំទុកដាក់សម្ភារ ឯកសារ ...... ៣៤

VI. **ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត** ...... ៣៤

១. ការចាត់ចែងរៀបចំបន្ទប់សម្រាប់រាប់សន្លឹកឆ្នោត ...... ៣៥

២.ករណីមានជនណាព្យាយាមធ្វើសកម្មភាពដោយទុច្ចរិត ក្នុងគោលបំណងចង់ដឹងថា តើអ្នកបោះឆ្នោតណាម្នាក់បានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ...... ៣៥

៣.សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ...... ៣៦

ក. សន្លឹកឆ្នោតបានការ ...... ៣៦

ខ. សន្លឹកឆ្នោតមិនបានការ ...... ៣៧

៤. កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ...... ៤៥

ក. ការរៀបចំសម្ភារ ឯកសារ ...... ៤៥

ខ. ការពិនិត្យហិបឆ្នោត នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ...... ៤៦

គ. ការរាប់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត ...... ៤៦

ឃ. ការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត ...... ៤៧

ង. ការកំណត់សុពលភាពសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការ ...... ៤៨

ច. ការកំណត់សុពលភាពចុងក្រោយនូវរាល់សន្លឹកឆ្នោតមិនបានការ ...... ៤៩

៥. ការបូកសរុបលទ្ធផល ការផ្ទៀងផ្ទាត់ និងការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោត ...... ៤៩

ក. ការបូកសរុបលទ្ធផល ...... ៤៩

ខ. រូបមន្តនៃការផ្ទៀងផ្ទាត់ ...... ៥០

៦. ការប្រើប្រាស់ ទ.១១០២ ទ.១១០៤ និងការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោងប្លាស្ទិក ...... ៥១

ក. ការប្រើប្រាស់ ទ.១១០២ និង ទ.១១០៤ ...... ៥១

ខ. ការវេចខ្ចប់ស្បោងប្លាស្ទិក ...... ៥២

VII. **ការរៀបចំ និងការវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ដាក់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធ** ....... ៥២
១. ការវេចខ្ចប់កញ្ចប់សុវត្ថិភាព «ក» .................................................. ៥២
២. ការវេចខ្ចប់ស្បោង «ខ» .................................................. ៥៣
ក. ដាក់ក្នុងស្បោង «ខ» .................................................. ៥៣
ខ. បំពេញលិខិតបញ្ជូន និងប្រគល់ ទទួល (ទ.១១០៧) .................................................. ៥៤
គ. ផ្ទៀងផ្ទាត់ ចងខ្សែ និងចាក់សោឃ្លុំមានលេខ .................................................. ៥៤
៣. ការវេចខ្ចប់សម្ភារៈ ឯកសារនៅសល់ បញ្ជូនទៅ គឃ.សប អមជាមួយស្បោង «ខ» .................................................. ៥៥
ក. ការរៀបចំវេចខ្ចប់កញ្ចប់សម្ភារៈ ឯកសារនៅសល់ .................................................. ៥៥
ខ. ការបំពេញលិខិតបញ្ជូន និងប្រគល់ ទទួល (ទ.១១០៧) ចុះហត្ថលេខាដោយប្រធាន គ.ក.រ ............ ៥៥
VIII. **ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈ ឯកសារបោះឆ្នោតនៅសល់ ទៅទីស្នាក់ការ គឃ.សប** .............. ៥៥
១. ការបញ្ជូនស្បោង «ខ» និងកញ្ចប់ដាក់សម្ភារៈ ឯកសារនៅសល់ទៅ គឃ.សប ក្នុងវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត .................................................. ៥៥
២. ការបញ្ជូនស្បោង «ខ» និងកញ្ចប់ដាក់សម្ភារៈ ឯកសារបោះឆ្នោតនៅសល់នៅព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ........ ៥៥
**ទម្រង់បែបបទសម្រាប់ប្រើប្រាស់ នៅ គ.ក.ប/គ.ក.រ** .................................................. ៥៦

# អក្សរកាត់

| | | |
|---|---|---|
| ១- | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២- | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៣- | លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| ៤- | គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ.សប |
| ៥- | គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| ៦- | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ច.ប.ត.រ |
| ៧- | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ប.ន.ត.រ |
| ៨- | ទម្រង់បែបបទលេខ | ទ. |
| ៩- | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១០- | ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត | ឯ.អ |

# គោលបំណង

ដើម្បីឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ នាថ្ងៃអាទិត្យ ទី២៩ ខែកក្កដា ឆ្នាំ២០១៨ ប្រព្រឹត្តទៅប្រកបដោយភាពរលូន ត្រឹមត្រូវតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គ.ជ.ប បានរៀបចំចងក្រង «សៀវភៅណែនាំ គ.ក.ប/គ.ក.រ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨» ដើម្បីណែនាំដល់មន្ត្រីពាក់ព័ន្ធនឹងការងារនេះ ឱ្យអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

សៀវភៅណែនាំនេះ ជាសេចក្តីពន្យល់អំពីបច្ចេកទេសលើចំណុចសំខាន់ៗនៃកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការវេចខ្ចប់ និងការបញ្ជូនរាល់សម្ភារឯកសារបោះឆ្នោតតាមលំដាប់លំដោយនៃការងារ។

គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ) ត្រូវយកចិត្តទុកដាក់សិក្សាស្វែងយល់តាមខ្លឹមសារនៃសៀវភៅណែនាំនេះ ដើម្បីអនុវត្តបច្ចេកទេសជាក់ស្តែងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឱ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងសម្រេចបានជោគជ័យ។ សៀវភៅណែនាំនេះក៏ជាជំនួយដ៏សំខាន់សម្រាប់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អ្នកសង្កេតការណ៍បោះឆ្នោត និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសិក្សាស្វែងយល់ និងរួមសហការអនុវត្តតាមតួនាទីរបស់ខ្លួន ដើម្បីឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។

# គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

## I. ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

ការិយាល័យបោះឆ្នោត នៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ដែលត្រូវបានកំណត់ និងផ្តល់សុពលភាពជាការិយាល័យបោះឆ្នោតផ្លូវការរួចរាល់ហើយដោយ គ.ជ.ប នឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោតនៅពេលរាប់សន្លឹកឆ្នោត។

ការិយាល័យបោះឆ្នោតត្រូវរៀបចំឱ្យមានច្រកចេញមួយ ច្រកចូលមួយ មានបរិវេណខាងក្នុង បរិវេណខាងក្រៅ និងមានភ្នាក់ងារសន្តិសុខបោះឆ្នោត។

### ១. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

គ.ក.ប ត្រូវបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែល គឃ.សប បានប្រគល់ឱ្យ នៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ នៅ ១ថ្ងៃមុនថ្ងៃបោះឆ្នោត។

### ២. បរិវេណខាងក្នុង

បរិវេណខាងក្នុងជាតំបន់ដែលនៅជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតហើយដែលខណ្ឌដោយរង្វង់មណ្ឌលមួយ មានកាំប្រវែងយ៉ាងតិច ១៥ម៉ែត្រ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចេញមួយ ច្រកចូលមួយ។

### ៣. បរិវេណខាងក្រៅ

បរិវេណខាងក្រៅជាតំបន់ដែលនៅជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលខណ្ឌដោយរង្វង់មណ្ឌលមួយ មានកាំប្រវែង ១០០ម៉ែត្រ ឬតូចជាងនេះ ស្របតាមស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជាបរិវេណរបងនៃសាលារៀន វត្តអារាម សាលមហោស្រព ឬទីសាធារណៈជាដើម។

នៅតំបន់ទីប្រជុំជន បរិវេណខាងក្រៅត្រូវបានកំណត់ដោយ គឃ.សប ដោយយោងលើការវាយតម្លៃអំពីស្ថានភាពសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងតំបន់នោះ។

នៅតំបន់ទីប្រជុំជន ក្នុងករណីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាំងនៅប្រមាណ ១០០ម៉ែត្រ ពីការិយាល័យបោះឆ្នោតមួយផ្សេងទៀត មួយផ្នែកនៃផ្លូវនេះត្រូវតែបិទចរាចរណ៍។

### ៤. ភ្នាក់ងារសន្តិសុខបោះឆ្នោត

នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួន ៣នាក់ ដែលការពារនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងឱ្យបានត្រឹមត្រូវ និងពាក់ប្រឡង់ដៃសន្តិសុខរបស់ គ.ជ.ប រហូតដល់ចប់ភារកិច្ច។

ភ្នាក់ងារសន្តិសុខបោះឆ្នោតមានភារកិច្ចការពារកុំឱ្យមានការរំខាន ការអុកឡុក ការបំភិតបំភ័យ និងការគំរាមកំហែង ឬហេតុការណ៍ផ្សេងៗដែលនឹងអាចកើតមាន និងត្រូវហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងនោះ ៖

- ភ្នាក់ងារសន្តិសុខបោះឆ្នោត ១នាក់ ត្រូវចល័តការពារជុំវិញបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលមានកាំប្រវែងយ៉ាងតិច ១៥ម៉ែត្រពីការិយាល័យបោះឆ្នោត និងមិនចាំបាច់ប្រើប្រាស់អាវុធ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ២នាក់ទៀត ត្រូវចល័តជុំវិញបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយត្រូវស្ថិតក្នុងចម្ងាយពី ១០០ម៉ែត្រ ឬទម្រង់ផ្សេង ឬមានកាំតូចជាង ស្របទៅតាមស្ថានភាពជាក់ស្តែងនៃបរិវេណខាងក្រៅរបស់ការិយាល័យនីមួយៗ អាចប្រើប្រាស់អាវុធវែង ១ដើម ដែលមានគ្រាប់យ៉ាងច្រើន៣០គ្រាប់។
- ក្នុងករណីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតច្រើន ប្រមូលផ្តុំនៅក្នុងបរិវេណ ឬអគារតែមួយ ចំនួនភ្នាក់ងារសន្តិសុខបោះឆ្នោតសម្រាប់ការិយាល័យនីមួយៗត្រូវសមស្របទៅនឹងស្ថានភាពជាក់ស្តែង ប៉ុន្តែមិនត្រូវឱ្យលើសពី ៣នាក់ក្នុងមួយការិយាល័យ។

**ចំណាំ៖**

ភ្នាក់ងារសន្តិសុខបោះឆ្នោត ឬ/និងភ្នាក់ងារសង្គ្រោះ (ក្រុមបុគ្គលិកពេទ្យ និងក្រុមពន្លត់អគ្គិភ័យ...) អាចចូលធ្វើអន្តរាគមន៍នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងករណីមានសំណូមពរចាំបាច់ពីប្រធាន គ.ជ.ប ប្រធាន គធ.ខប ប្រធាន គឃ.សប ឬប្រធាន គ.ក.ប/គ.ក.រ។

## ៩. វិធានការសន្តិសុខ

ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ឱ្យចៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខាន ការអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង ឬក៏ហេតុការណ៍អសន្តិសុខផ្សេងៗដែលនឹងអាចកើតមានជាថៃដន្យ និងដើម្បីរក្សាការពារឧបករណ៍ សម្ភារ ឯកសារបោះឆ្នោតទាំងអស់នៅក្នុងការិយាល័យទាំងនោះ ប្រធាន គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានា ដូចខាងក្រោម៖

- ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ព្រមទាំងការស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធ ចូលទៅក្នុងបរិវេណខាងក្រៅ

បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងតែក្នុងករណីមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលប្រធាន គ.ជ.ប ឬ/និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ មានភារកិច្ចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច។

- ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោត មុនពេលចាប់ផ្តើមការបោះឆ្នោត ឬក្រោយពេលបិទការបោះឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។
- ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម៖
  - មន្ត្រីបោះឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប។
  - ភ្នាក់ងារគណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងដែលត្រូវបានអនុញ្ញាត។
  - អ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប។
  - អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប។
  - អ្នកដែលមានសិទ្ធិបោះឆ្នោត ហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។
  - ជនដែលអមដំណើរអ្នកបោះឆ្នោតមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង។
  - ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.ប មានសំណូមពរ ក្នុងករណីចាំបាច់។
- ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត មុនពេលចាប់ផ្តើមការរាប់សន្លឹកឆ្នោត ឬក្រោយការរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។
- ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម៖
  - មន្ត្រីរាប់សន្លឹកឆ្នោត ដែលបានទទួលការតែងតាំងពី គ.ជ.ប។
  - ភ្នាក់ងារគណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងដែលត្រូវបានអនុញ្ញាត។
  - អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប។
  - ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.រ ធ្វើសំណូមពរក្នុងករណីចាំបាច់។

- សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖
  ▪ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ។
  ▪ ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យអ្នកបោះឆ្នោត បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ។
  ▪ ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ។
- សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ៖
  ▪ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ។
  ▪ ការផ្សព្វផ្សាយ ឬការនិយាយអ្វី ដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីរាប់សន្លឹកឆ្នោត រាប់គំនូសនៅលើសន្លឹកឆ្នោត ដើម្បីបំពេញចិត្ត ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនណាមួយ។

**ចំណាំ៖**

- ក្នុងករណីមានការរំខានដល់ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ប្រធាន គ.ក.ប/គ.ក.រ ត្រូវហាមជនគ្រប់រូបចូលក្នុងបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែក ដើម្បីធានាឱ្យការបោះឆ្នោត និងរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព។
- ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គ.ក.ប/គ.ក.រ។
- ចំពោះការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបានក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន គ.ជ.ប ត្រូវសម្រេចឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះនៅកន្លែងផ្សេងទៀត។ គ.ជ.ប ត្រូវផ្សព្វផ្សាយជាបន្ទាន់ និងជាសាធារណៈអំពីសេចក្តីសម្រេចនេះ។

## II. គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ)

### ១. សមាសភាព គ.ក.ប

សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត មានចំនួន ៦រូប គឺប្រធាន ១រូប អនុប្រធាន ១រូប លេខាធិការ ១រូប សមាជិក ៣រូប។ សមាជិក គ.ក.ប ទាំងអស់ ត្រូវចូលរួមវគ្គបណ្តុះបណ្តាល និងម្ចាស់ការអនុវត្តរាល់នីតិវិធីនៃដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

### ២. ការទទួលខុសត្រូវ និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ

គ.ក.ប នឹងក្លាយទៅជា គ.ក.រ នៅពេលរាប់សន្លឹកឆ្នោត។ គ.ក.ប/គ.ក.រ នីមួយៗ មានភារកិច្ចចាត់ចែងគ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតដែល គ.ក.ប/គ.ក.រ នោះទទួលខុសត្រូវ។

ការទទួលខុសត្រូវ និងភារកិច្ចរបស់សមាជិក គ.ក.ប/គ.ក.រ ទាំងអស់មានលម្អិតស្រាប់នៅក្នុងសកម្មភាពជាក់ស្តែងនៃដំណាក់កាលនីមួយៗ។

## III. ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប សម្ភារ ឯកសារ និងទីតាំងការិយាល័យបោះឆ្នោត (នៅថ្ងៃសៅរ៍ ១ថ្ងៃមុនថ្ងៃបោះឆ្នោត)

គ.ជ.ប ត្រូវធានាថា រាល់សម្ភារ ឯកសារបោះឆ្នោត ត្រូវបានបញ្ជូន និងប្រគល់ជូន គ.ក.ប មិនឱ្យលើសពី ៣៦ម៉ោងមុនថ្ងៃបោះឆ្នោត។

នៅពេលព្រឹកនៃថ្ងៃមុនថ្ងៃបោះឆ្នោត ប្រធាន គ.ក.ប ត្រូវកោះប្រជុំសមាសភាពទាំងអស់នៃ គ.ក.ប ឱ្យមកបង្ហាញខ្លួននៅទីតាំងការិយាល័យបោះឆ្នោត ដើម្បីពិនិត្យវត្តមាន ត្រួតពិនិត្យសម្ភារ បរិក្ខារបម្រើឱ្យការបោះឆ្នោត និងរៀបចំគំរូប្លង់ការិយាល័យបោះឆ្នោត។ ក្នុងករណីបើមានមន្ត្រីណាម្នាក់អវត្តមាន មន្ត្រីនោះត្រូវជំនួសដោយមន្ត្រីថ្មីដែលជ្រើសតាំងឡើង តាមការសម្រេចរបស់ គឃ.សប ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។

### ១. ការត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប

ប្រធាន គ.ក.ប ត្រូវត្រួតពិនិត្យវត្តមានសមាសភាព គ.ក.ប ដើម្បី៖

- ឱ្យដឹងថា តើសមាជិក គ.ក.ប មានវត្តមានគ្រប់ទាំង ៦រូប ឬទេ ឬមានសមាជិកណាមួយ ឬច្រើនមិនអាចមកបំពេញការងារបាននៅថ្ងៃបោះឆ្នោត។
- ចាត់តាំងសមាជិកឱ្យទទួលខុសត្រូវក្នុងការរៀបចំសម្ភារ ឯកសារបោះឆ្នោត តាមតួនាទីរៀងៗខ្លួន។
- ឱ្យសមាជិកម្នាក់ៗរំឭកឡើងវិញអំពីតួនាទី ភារកិច្ចដែលត្រូវបំពេញនៅថ្ងៃបោះឆ្នោត និងដែលមានចែងក្នុងសៀវភៅណែនាំនេះ។

**ចំណាំ៖**

- ប្រសិនបើសមាសភាពណាម្នាក់នៃ គ.ក.ប មិនអាចមកបំពេញការងារក្នុងថ្ងៃបោះឆ្នោត ប្រធានត្រូវតែជូនដំណឹងដល់ គឃ.សប ជាបន្ទាន់ដើម្បីដាក់អ្នកជំនួស៖

- ប្រសិនបើប្រធានមិនអាចមកបំពេញការងារបាន ដោយសារមូលហេតុសំខាន់ណាមួយនោះ អនុប្រធានត្រូវចូលកាន់តំណែងប្រធាន ហើយសមាជិកទី ១ ចូលកាន់តំណែងអនុប្រធាន ចំណែកអ្នកដែលត្រូវជ្រើសរើសថ្មីចេញពីក្នុងចំណោមប្រជាពលរដ្ឋដែលបានដាក់ពាក្យសម្ភាសន៍ ត្រូវចូលកាន់តំណែងជួសសមាជិកទី១។
- ប្រសិនបើអនុប្រធាន មិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងសមាជិកទី១ ជាអនុប្រធាន ហើយអ្នកដែលត្រូវជ្រើសរើសថ្មី នឹងកាន់តំណែងជាសមាជិកទី១។
- ប្រសិនបើលេខាធិការ មិនអាចមកធ្វើការបាន ត្រូវតែងតាំងសមាជិកទី១ ជាលេខាធិការ ហើយអ្នកដែលត្រូវជ្រើសរើសថ្មី នឹងកាន់តំណែង ជាសមាជិកទី១។

- សមាសភាពទាំងអស់នៃ គ.ក.ប រួមទាំងអ្នកដែលទើបតែជ្រើសរើសថ្មី ត្រូវរួមគ្នាសិក្សាឡើងវិញ នូវនីតិវិធីនៃការបោះឆ្នោត ដែលមានចែងក្នុងសៀវភៅណែនាំ គ.ក.ប/គ.ក.រ។
- ប្រធាន គ.ក.ប ត្រូវតែជូនដំណឹងជាបន្ទាន់ដល់ គឃ.សប អំពីអ្វីដែលបានអនុវត្តពាក់ព័ន្ធនឹងការដាក់ជួសតំណែងណាមួយនៃ គ.ក.ប។

## ២. ការទទួល និងការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត

### ក. សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែល គ.ក.ប ត្រូវទទួល

- បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធចំនួន ២ច្បាប់។
- សន្លឹកឆ្នោតមួយកញ្ចប់ដែលត្រូវបានវេចខ្ចប់ដោយខ្សែក និងអមដោយត្រាសម្ងាត់១ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ដែលដាក់ក្នុងស្រោមសំបុត្របិទជិតសម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ។
- ហិបឆ្នោតមួយដែលមិនទាន់ដំឡើង និងវេចខ្ចប់ដោយខ្សែក។
- បន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ចំនួន២ ដែលមិនទាន់ដំឡើង និងវេចខ្ចប់ច្រកក្នុងការុងនីឡុងមួយដោយខ្សែក និងអមដោយស្កុត ១ដុំផង។
- រាល់សម្ភារ ឯកសារបម្រើការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតត្រូវបានដាក់ក្នុងកេសស័ង្កសីមួយ។ សម្ភារ ឯកសារទាំងនេះ រួមមាន ៖
  - លេខកូដការិយាល័យបោះឆ្នោតចំនួន ២ច្បាប់ សម្រាប់បិទនៅខាងមុខការិយាល័យបោះឆ្នោតចំនួន ១ច្បាប់ និងសម្រាប់បិទខាងមុខហិបឆ្នោតចំនួន ១ច្បាប់។
  - ស្លាកសម្គាល់ «ការិយាល័យបោះឆ្នោត» បោះពុម្ពលើកំណាត់ប្លាស្ទិក ចំនួន ១។
  - បណ្ណប្រកាសហាមប្រើប្រាស់ទូរស័ព្ទដៃ ម៉ាស៊ីនថតចំនួន ២សន្លឹក។
  - ទឹកខ្មៅលុបមិនជ្រះចំនួន ២ដប។
  - ត្រាការិយាល័យបោះឆ្នោត ចំនួន ១។
  - តាំប៉ុងពណ៌ក្រហម ចំនួន ១ប្រអប់ និងទឹកតាំប៉ុងក្រហម ចំនួន ១ដប។
  - ប៊ិកមានខ្សែចងសម្រាប់គូសសន្លឹកឆ្នោត និងប៊ិកធម្មតាសម្រាប់ គ.ក.ប សរុបទាំងពីរមុខ ចំនួន ៨ដើម។
  - ប៊ិកហ្វឺតធំលុបមិនជ្រះ ចំនួន ១ដើម។

- ប៊ិកហ្វឺតធំ ចំនួន ១ដើម។
- បន្ទាត់ជ័រ ចំនួន ១ដើម។
- ប្រដាប់ចោះសន្លឹកឆ្នោត ចំនួន ១។
- ជ័រការពារ ចំនួន ១ដប។
- ស្កុតថ្លាធំចំនួន ១ដុំ។
- កៅស៊ូកងមួយចំនួន សម្រាប់ចងសន្លឹកឆ្នោតតាមគណបក្ស។
- ស្រោមសំបុត្រធំ ចំនួន ១ មធ្យម១០ និងតូច ២។
- ក្រដាសស្តើង សម្រាប់បិទពាសសន្ទះបិទប្រឡោះស៊ិកសន្លឹកឆ្នោតចំនួន ៦សន្លឹក។
- ក្រដាសរ៉ាម សម្រាប់ប្រើប្រាស់ការងារផ្សេងៗ ចំនួន ២០សន្លឹក។
- ក្របក្រដាសពិសេសសម្រាប់អ្នកបោះឆ្នោតពិការភ្នែកទាំងសងខាងបោះឆ្នោតដោយខ្លួនឯងចំនួន ១។
- ផ្ទាំងក្រដាស សម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ចំនួន ២ផ្ទាំង។
- ផ្ទាំងក្រដាសធំ សម្រាប់កត់ត្រាសំឡេងឆ្នោត ១ផ្ទាំង។
- ទ.១១០១ ចំនួន ៦ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត។
- ទ.១១០២ ចំនួន ២០ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។
- ទ.១១០៧ ចំនួន ៦ច្បាប់ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត។
- ទ.១១០៨ ចំនួន ៤ច្បាប់ សម្រាប់កត់ត្រាសំឡេងឆ្នោត។
- ទ.១១១២ ចំនួន ៤ច្បាប់ សម្រាប់បំពេញតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតដែល គ.ក.ប បានទទួល។
- ទ.១១១៥ ចំនួន ២ច្បាប់ សម្រាប់ស្រង់វត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត។
- ទ.១១២០ ចំនួន ២ច្បាប់ សម្រាប់ស្រង់វត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត។
- ទ.១២០២ ចំនួន ២ក្បាល ក្នុងមួយក្បាលមាន ២០ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់។
- ស្បោងប្លាស្ទិក សម្រាប់ដាក់សន្លឹកឆ្នោតដែលមិនបានប្រើ និងគល់សន្លឹកឆ្នោតដែលប្រើហើយចំនួន១។
- ស្បោងប្លាស្ទិក សម្រាប់ដាក់សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការចំនួន ១។
- កញ្ចប់សុវត្ថិភាព «ក» សម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោត ចំនួន១។
- ស្បោង«ខ»សម្រាប់ដាក់កញ្ចប់សុវត្ថិភាព«ក»និងសម្ភារឯកសារបោះឆ្នោតចំនួន១។

- សោឃ្លុំជ័រតូចមានលេខសម្រាប់បិទគម្របខាងក្នុង និងខាងក្រៅនៃហិបឆ្នោត ចំនួន ៣។
- សោឃ្លុំជ័រមធ្យមមានលេខសម្រាប់ឃ្លុំបិទមាត់ស្បោង «ខ» ចំនួន ១។

**ខ. ការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

គ.ក.ប ត្រូវត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែល គ.ក.ប បានទទួល ហើយដែលមានរាយមុខនៅក្នុង ទ.១១០៧ ក្នុងនោះត្រូវ៖

- ត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារ ឯកសារបោះឆ្នោតដោយប្រើ ទ.១១១២ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោត ដែលបានទទួលមានចំនួនគ្រប់គ្រាន់ហើយ សមាសភាពទាំងអស់នៃ គ.ក.ប ត្រូវចុះហត្ថលេខាលើ ទ.១១១២ និងរក្សាទុកឱ្យបានហ្មត់ចត់។
- ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតណាមួយ ឬច្រើនដែលបានទទួលនោះមិនមានចំនួនគ្រប់គ្រាន់ លេខាធិការត្រូវបំពេញត្រង់ផ្នែកសម្ភារ ឯកសារបោះឆ្នោតដែលបាត់បង់ នៅក្នុង ទ.១១១២ ហើយផ្ញើ ទ.១១១២ នេះ ចំនួន ១ច្បាប់ ជាបន្ទាន់ទៅ គឃ.សប។
- ប្រសិនបើសម្ភារ ឯកសារដែលបាត់បង់ទៅនោះជាសម្ភារ ឯកសារសំខាន់សម្រាប់ការបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិក ២រូប ឱ្យទៅកាន់ទីស្នាក់ការ គឃ.សប ដើម្បីទទួលសម្ភារ ឯកសារថ្មីជំនួសសម្ភារ ឯកសារដែលខ្វះ ឬបានបាត់បង់ទៅ លើកលែងតែមានវិទ្យុទាក់ទង ឬទូរស័ព្ទ ដែលអាចបញ្ជូនព័ត៌មានស្នើសុំ គឃ.សប ដោះស្រាយបាន។
- គ.ក.ប ត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យសម្ភារសំខាន់ៗ ដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត។ សម្ភារសំខាន់ៗទាំងនោះ រួមមាន៖
  - សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់។
  - ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត។
  - បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។
  - ហិបឆ្នោត និងសោឃ្លុំមានលេខ។
  - ទឹកខ្មៅលុបមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃ។
- ចំពោះសម្ភារដទៃទៀត ប្រសិនបើមិនបានផ្តល់ដោយ គឃ.សប ទេនោះ គ.ក.ប ត្រូវច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង ដូចជា៖
  - កន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាចប្រើជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

▪ ក្រដាសសម្រាប់សរសេរកំណត់ហេតុដោយដៃ ដែលអាចជំនួសទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុគំរូ។
▪ ប៊ិកសរសេរ បន្ទាត់ កន្ត្រៃ ខ្សែចង...។

**ចំណាំ៖**

ប្រធាន គ.ក.ប ត្រូវ៖

- ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យប្រាកដថា ជាកញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នោះ ហើយគ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ចំនួន និងលេខរៀងដែលកត់ត្រានៅលើកញ្ចប់សន្លឹកឆ្នោតប៉ុណ្ណោះ ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតជាដាច់ខាត។
- ពិនិត្យស្រោមសំបុត្រដាក់ត្រាសម្ងាត់ឱ្យប្រាកដថា ពិតជាមានត្រាសម្ងាត់នៅខាងក្នុង ប៉ុន្តែមិនត្រូវបើកស្រោមសំបុត្រជាដាច់ខាត។
- ចាត់ចែងសមាជិកឱ្យហាត់ដំឡើងហិបឆ្នោត និងបន្ទប់សម្ងាត់។

**គ. ការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ និងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត**

*ប្រធាន គ.ក.ប ត្រូវ*

- *ចាត់សមាជិកទី២ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ១ច្បាប់ និងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ១ច្បាប់ នៅមុខទីតាំងការិយាល័យបោះឆ្នោត។*
- *លើកស្លាក និងបិទលេខកូដការិយាល័យបោះឆ្នោត នៅនឹងមាត់ច្រកចូលការិយាល័យបោះឆ្នោត។*

**ឃ.ការរក្សាការពារសម្ភារ ឯកសារបោះឆ្នោត**

*ប្រធាន គ.ក.ប ត្រូវ*

- *រក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅផ្ទះប្រធាន ឬផ្ទះសមាជិកណាម្នាក់ ឬនៅទីតាំងណាមួយដែល គ.ក.ប ឯកភាពគ្នាថាមានសុវត្ថិភាព និងជូនដំណឹងដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍។*
- *ចាត់សមាជិក គ.ក.ប ៣នាក់ គិតទាំងប្រធាន ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាពសម្ភារ ឯកសារបោះឆ្នោត។*
- *ស្នើសុំកម្លាំងសន្តិសុខ ដើម្បីរួមសហការការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលទទួលរក្សាទុកសម្ភារ ឯកសារបោះឆ្នោត។*

## ៣. ការរៀបចំការិយាល័យបោះឆ្នោត

ប្រធាន គ.ក.ប ត្រូវរៀបចំការិយាល័យបោះឆ្នោតឱ្យបានរួចរាល់នៅថ្ងៃសៅរ៍ មួយថ្ងៃមុនថ្ងៃបោះឆ្នោត តាមគំរូប្លង់ដែលបានកំណត់ ដើម្បីឱ្យប្រាកដថា សមាជិកម្នាក់ៗនៃ គ.ក.ប អាចរៀបចំសម្ភារ ឯកសារបោះឆ្នោតទៅតាមកន្លែងរៀងៗខ្លួនឱ្យរួចស្រេចនៅម៉ោង ៦:០០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត។ ប្រធាន គ.ក.ប ត្រូវចាត់ចែងៈ

- បោសសម្អាតការិយាល័យ។
- រៀបចំតុ កៅអី និងសម្ភារដទៃទៀតឱ្យមានចំនួនគ្រប់គ្រាន់ សម្រាប់ដំណើរការបោះឆ្នោត ប្រសិនបើគ្មាន ឬមានចំនួនមិនគ្រប់គ្រាន់ ប្រធានត្រូវធ្វើសំណើសុំខ្ចីពីអាជ្ញាធរមូលដ្ឋានជាបន្ទាន់ ដើម្បីជួយសម្រួលដល់ការងារបោះឆ្នោត។
- រៀបចំបន្ទប់ឱ្យមានច្រកចេញមួយ និងច្រកចូលមួយ។
- បិទបង្អួចចាក់សោទ្វារ(ប្រសិនបើអាចធ្វើបាន) និងស្នើសុំកម្លាំងសន្តិសុខយាមការពារ។
- ណាត់សមាជិកទាំងអស់ឱ្យមកកាន់ទីកន្លែងរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅម៉ោង ៥:៣០ នាទីព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដើម្បីជួយដឹកជញ្ជូនសម្ភារឯកសារបោះឆ្នោតទៅកាន់ទីតាំងការិយាល័យបោះឆ្នោត។
- ជម្រាបសមាជិកទាំងអស់នៃ គ.ក.ប ឱ្យត្រៀមអាហារសម្រាប់រយៈពេល ១ថ្ងៃសម្រាប់ហូបនៅពេលទំនេរ ដែលពុំមានអ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប។

### គំរូប្លង់ការិយាល័យបោះឆ្នោត



៤. ការប្រើប្រាស់បញ្ជីបោះឆ្នោតផ្លូវការ

*បញ្ជីបោះឆ្នោតផ្លូវការ សម្រាប់ គ.ក.ប ២ច្បាប់*
- *១ច្បាប់ បិទនៅមុខទីតាំងការិយាល័យបោះឆ្នោត នៅថ្ងៃសៅរ៍ ១ថ្ងៃមុនថ្ងៃបោះឆ្នោត។*
- *១ច្បាប់ ទុកប្រើប្រាស់នៅថ្ងៃបោះឆ្នោត។*

## IV. ការប្រព្រឹត្តទៅនៃការបោះឆ្នោត

សមាសភាព គ.ក.ប ទាំងអស់ ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោត នៅម៉ោង ៦:០០ នាទីព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដើម្បីគ្រប់គ្រង និងចាត់ចែងការបោះឆ្នោត។

បន្ទាប់ពី គ.ក.ប បានចូលដល់ក្នុងការិយាល័យបោះឆ្នោតភ្លាម ប្រធាន គ.ក.ប ត្រូវៈ

- ប្រកាសអញ្ជើញភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដោយត្រូវពិនិត្យបណ្ណសម្គាល់ ឬសេចក្តីសម្រេចតែងតាំង និងទទួលស្គាល់ជាផ្លូវការម្នាក់ម្តងៗ និងប្រាប់ទីកន្លែង ដែលបានបម្រុងទុកជូន។
- ចាត់ចែងសមាជិក គ.ក.ប ឱ្យរៀបចំគ្រឿងសង្ហារិម សម្ភារ ឯកសារបោះឆ្នោត តាមតួនាទីភារកិច្ច និងតាមទីកន្លែងរៀងៗខ្លួនតាមគំរូប្លង់ដែលបានរៀបចំទុក ១ថ្ងៃមុនថ្ងៃបោះឆ្នោត។
- ចាត់ចែង និងណែនាំសមាជិកទី២ ឱ្យបំពេញការងាររបស់ខ្លួននៅបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត។

### ១. ការរៀបចំសម្ភារ ឯកសារបោះឆ្នោត និងការពន្យល់ណែនាំជាំរួមដល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន

#### ក. ការរៀបចំសម្ភារ ឯកសារបោះឆ្នោត

- តុ១ នៅខាងឆ្វេងដៃ បន្ទាប់ពីផ្លូវចូលសម្រាប់ប្រធាន។

*កន្លែងប្រធានមាន*
- *ទ.១២០២ (ពាក្យបណ្តឹង)។*
- *ទ.១១២០ សម្រាប់អ្នកសង្កេតការណ៍ចុះហត្ថលេខា។*
- *ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលមានសម្ភារ ឯកសារមិនទាន់ប្រើប្រាស់ ត្រូវដាក់នៅក្បែរតុប្រធាន។*

- តុវែង១ ឬតុតូច២ ដាក់ជាប់គ្នានៅខាងស្តាំដៃបន្ទាប់ពីផ្លូវចូល សម្រាប់លេខាធិការ និងអនុប្រធានអង្គុយជាប់គ្នា។

*កន្លែងលេខាធិការមាន*
- *បញ្ជីបោះឆ្នោត ១ច្បាប់។*
- *កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ចំនួន ៣ច្បាប់។*
- *ត្រាការិយាល័យបោះឆ្នោត និងទម្រង់បែបបទផ្សេងៗទៀត។*

*កន្លែងអនុប្រធានមាន*
- *កញ្ចប់សន្លឹកឆ្នោត។*
- *ស្រោមសំបុត្រដាក់ត្រាសម្ងាត់ និងតាំប៉ុងពណ៌ក្រហម។*

- បន្ទប់សម្ងាត់២ ដាក់នៅលើតុ២ ក្បែរជញ្ជាំង ប្រមាណ ១,៥០ម៉ែត្រ ពីជញ្ជាំង និងមានចម្ងាយពីគ្នាយ៉ាងតិច ១ម៉ែត្រ ប៉ុន្តែមិនត្រូវដាក់នៅក្បែរបង្អួចទេ។

| | |
|---|---|
| *បន្ទប់សម្ងាត់ពីរ ក្នុងបន្ទប់នីមួយៗមាន* | *- ប៊ិក ១ដើម ចងខ្សែភ្ជាប់ស្រាប់។*<br>*- ក្រដាសទ្រនាប់ ១សន្លឹក ពាសនៅលើតុសម្រាប់ទ្រាប់គូសសន្លឹកឆ្នោត។* |

- តុវែង១ សម្រាប់សមាជិកទី១ ដាក់នៅកណ្តាលបន្ទប់ទល់មុខតុប្រធាន។

| | |
|---|---|
| *តុសមាជិកទី១ មាន* | *- ហិបឆ្នោតដំឡើងរួច។*<br>*- ទឹកខ្មៅលុបមិនជ្រះចំនួន ២ដប។*<br>*- កំណាត់សម្រាប់ជូតម្រាមដៃអ្នកបោះឆ្នោត។* |

- តុ និងកៅអីសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ (បើមាន) ដាក់នៅអែបជញ្ជាំងប៉ែកខាងឆ្វេងដៃនៃតុរបស់ប្រធាន និងនៅក្រោយតុអនុប្រធាន និងលេខាធិការ។

**ចំណាំះ**

- គ.ក.ប ត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ស្ថិតនៅទីជិតខាងក្រោយអនុប្រធាន និងលេខាធិការ ល្មមដែលអាចមើលឃើញឯកសារបាន។
- ការផ្លាស់ប្តូរទីកន្លែងឈរ ឬអង្គុយរបស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវមានការអនុញ្ញាតពីប្រធាន គ.ក.ប។

### ខ. ការពន្យល់ណែនាំជារួមដល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន

ប្រធាន គ.ក.ប ត្រូវណែនាំជារួមដល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន ដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗ ដែលត្រូវអនុវត្ត ដូចខាងក្រោម ៖

- ត្រូវគោរព ច.ប.ត.រ ប.ន.ត.រ ក្រមសីលធម៌សម្រាប់គណបក្សនយោបាយបេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត និងក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ដែលកំណត់ដោយ គ.ជ.ប។
- ត្រូវតាមដានជាប្រចាំកិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោត បង្ការក្រែងមានករណីមិនប្រក្រតីក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។
- ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត។
- មិនត្រូវណែនាំ ឬស្តីបន្ទោសអ្វីដល់សមាសភាព គ.ក.ប/គ.ក.រ។
- មិនត្រូវណែនាំ ឬសាកសួរអ្វីចំពោះអ្នកបោះឆ្នោត។
- មិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ។

- ត្រូវលើកសំណួរ សំណូមពរផ្សេងៗ ឬ/និងយោបល់ជំទាស់ដោយផ្ទាល់ទៅប្រធាន គ.ក.ប/គ.ក.រ ចំពោះភ្នាក់ងារគណបក្សនយោបាយ។
- ត្រូវបំពេញវត្តមានអ្នកសង្កេតការណ៍ក្នុងពេលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត (ទ.១១២០) ដោយត្រូវបញ្ជាក់ឈ្មោះសាមីអង្គការ ម៉ោងចូល ម៉ោងចេញ និងចុះហត្ថលេខា។

**២. នាវកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:០០ នាទីដល់ម៉ោង ៦:៣០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត**

*ប្រធាន គ.ក.ប ត្រូវ*

- *ប្រកាសដល់អ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោត ហាមប្រើទូរស័ព្ទដៃ ឬ/និងម៉ាស៊ីនថត ឬ/និងឧបករណ៍ផ្សេងទៀតដែលអាចថតរូបបាន និងហាមធ្វើសកម្មភាពរំលោភលើការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត។*
- *ជម្រាបអ្នកយកព័ត៌មានដែលបានទទួលស្គាល់ដោយ គ.ជ.ប ថាគាត់អាចថតយកសកម្មភាពនៅការិយាល័យបោះឆ្នោតបាន ប៉ុន្តែមិនត្រូវរំលោភលើការសម្ងាត់នៃការបោះឆ្នោត និងត្រូវស្នើសុំការអនុញ្ញាតជាមុន។*
- *ពិនិត្យឡើងវិញនូវហិបឆ្នោត ដើម្បីឱ្យប្រាកដថា ត្រូវបានដំឡើងត្រឹមត្រូវតាមការណែនាំ។*
- *បើកគម្របក្រៅ និងគម្របក្នុងនៃហិបឆ្នោត។*
- *បង្ហាញហិបឆ្នោតទទេ ចំពោះអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកបិទគម្របក្នុងនៃហិបឆ្នោត រួចបិទភ្ជិតគម្របសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ខ្ទាស់គន្លឹះគម្របក្នុង និងចាក់សោឃ្លុំមានលេខ។*

*ប្រធាន គ.ក.ប ត្រូវ*

- *ចាត់លេខាធិការឱ្យកត់ត្រាលេខសោឃ្លុំនៅលើ ទ.១១០១។*
- *យកក្រដាសលេខកូដការិយាល័យបោះឆ្នោតចំនួន ១សន្លឹក បោះត្រាការិយាល័យបោះឆ្នោតរួចបិទភ្ជាប់ទៅនឹងជញ្ជាំងមុខនៃហិបឆ្នោត។*
- *អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ពិនិត្យមើល និងកត់ចំណាំហិបឆ្នោត។*
- *ចាត់លេខាធិការឱ្យកត់ត្រា ពេលម៉ោងនៃការពិនិត្យហិបឆ្នោតនៅលើ ទ.១១០១។*

**ចំណាំ៖**

- មិនអនុញ្ញាតឱ្យយកហិបឆ្នោតចេញពីការិយាល័យបោះឆ្នោត។
- មិនអនុញ្ញាតឱ្យបើកហិបឆ្នោតដាច់ខាត។
- សមាជិកទី២ នៅខាងក្រៅការិយាល័យបោះឆ្នោតអាចប្រើប្រាស់ទូរស័ព្ទបាន ដើម្បីទំនាក់ទំនងការងារ។

ប្រធាន គ.ក.ប បង្ហាញហិបឆ្នោតទទេដល់សមាជិក គ.ក.ប ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍




ហិបឆ្នោតដែលមានចាក់ទ្លាប់សោឃុំមានលេខត្រង់គន្លឹះ




**៣. នារកិច្ចរបស់ គ.ក.ប នៅចន្លោះពីម៉ោង ៦:៣០ នាទីដល់ម៉ោង ៧:០០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត**

ប្រធាន គ.ក.ប ត្រូវចាត់ចែងត្រួតពិនិត្យកញ្ចប់សន្លឹកឆ្នោត លេខរៀងសន្លឹកឆ្នោត រាប់ចំនួនសន្លឹកឆ្នោត ដែលបានទទួលជាក់ស្តែង និងពិនិត្យត្រាសម្ងាត់ផ្លូវការនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត។

## ក. ការត្រួតពិនិត្យកញ្ចប់សន្លឹកឆ្នោត

| | |
|---|---|
| ប្រធាន គ.ក.ប ត្រូវ | - ចាត់អនុប្រធានឱ្យ៖<br>▪ ត្រួតពិនិត្យមើលកញ្ចប់សន្លឹកឆ្នោត ដើម្បីឱ្យដឹងប្រាកដថា សន្លឹកឆ្នោតនេះជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៃមណ្ឌលរាជធានី ខេត្តរបស់ខ្លួនប្រាកដមែន។ ប្រសិនបើមិនមែន ប្រធាន គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់ តាមរយៈ គឃ.សប និង គធ.ខប ជូន គ.ជ.ប ដើម្បីមានវិធានការដោះស្រាយ។<br>▪ បើកកញ្ចប់សន្លឹកឆ្នោត រួចរាប់សន្លឹកឆ្នោតដែលជាធម្មតាមានចំនួនលើសចំនួនអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ក្នុងចន្លោះពី២៥ ដល់ ៧៥សន្លឹក។<br>- ចាត់លេខាធិការឱ្យ៖<br>▪ កត់ត្រាចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញជាក់ស្តែង(ទោះបីសន្លឹកឆ្នោតរាប់ឃើញជាក់ស្តែងមានចំនួនលើស ឬខ្វះ ធៀបនឹងចំនួនសន្លឹកឆ្នោតដែលត្រូវប្រគល់ឱ្យក្តី) និងកត់ត្រាលេខរៀងសន្លឹកឆ្នោតដំបូងនៃក្បាលទី១ និងលេខរៀងសន្លឹកចុងក្រោយនៃក្បាលចុងក្រោយទៅក្នុង ទ.១១០១។<br>▪ ពិនិត្យចំនួនអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោត និងកត់ត្រាចំនួននេះទៅក្នុង ទ.១១០១។ |

## ខ. ការបង្ហាញត្រាសម្ងាត់

| | |
|---|---|
| ប្រធាន គ.ក.ប ត្រូវ | - បើកស្រោមសំបុត្រដែលមានត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត។<br>- ដកយកត្រានោះ មកបោះសាកល្បងនៅលើក្រដាសធម្មតាពណ៌ស និងលើកបង្ហាញអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់ឱ្យបានឃើញច្បាស់ និងចំណាំបានរូបសញ្ញានៃត្រានោះ។ |

**ចំណាំ៖**

*ករណីសម្ភារ ឯកសារបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោត ត្រូវបានទទួលនៅក្រោយម៉ោង ៦:៣០ នាទីព្រឹក ប៉ុន្តែមិនហួសពីម៉ោង ៧:០០ នាទីព្រឹកនៃថ្ងៃបោះឆ្នោតទេ ប្រធាន គ.ក.ប ត្រូវ៖*

- *ព្យួរការអនុវត្តនីតិវិធីនៃការពិនិត្យកញ្ចប់សន្លឹកឆ្នោត និងការបង្ហាញត្រាសម្ងាត់ជាបណ្តោះអាសន្នសិន រហូតទាល់តែនីតិវិធីនៃការពិនិត្យ និងបង្ហាញហិបឆ្នោតត្រូវបានបំពេញចប់សព្វគ្រប់។*

- ចាត់លេខាធិការកត់ត្រាពេលម៉ោងនៃការពិនិត្យ និងបង្ហាញហិបឆ្នោត និងកត់ត្រាចំនួន និងលេខរៀងសន្លឹកឆ្នោត ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតទៅក្នុង ទ.១១០១ ឱ្យបានច្បាស់លាស់។
- បើកការិយាល័យបោះឆ្នោតនៅក្រោយម៉ោង ៧:០០ នាទីព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោង ៨:០០ នាទីព្រឹកឡើយ។

## ៨. ការបោះឆ្នោត និងឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត

ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវះ

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោត។
- មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) ឆ្នាំ២០១៧ ដែលមានបញ្ជាក់ពី គឃ.សប។

**អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ទាំង ៣ប្រភេទ**



ឬ



ឬ



ឬ

**ឯកសារបញ្ជាក់អត្តសញ្ញាណ បម្រើឱ្យការបោះឆ្នោត (ឯ.អ)**



ឬ

**ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) ឆ្នាំ២០១៧ ដែលមានបញ្ជាក់ពី គឃ.សប**



## ៥. រយៈពេលបោះឆ្នោត៖ ចាប់ពីម៉ោង ៧:០០ នាទីព្រឹកដល់ម៉ោង ៣:០០ នាទីរសៀល




ប្រធាន គ.ក.ប ត្រូវប្រកាសបើកការិយាល័យបោះឆ្នោតនៅម៉ោង ៧:០០ នាទីព្រឹកនៃថ្ងៃបោះឆ្នោត រួចអញ្ជើញសមាសភាព គ.ក.ប ឱ្យបោះឆ្នោតមុនគេបង្អស់ បន្ទាប់មកភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាន ប្រសិនបើអ្នកទាំងនោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។ ប្រធាន គ.ក.ប ត្រូវចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត។ យ៉ាងយូរ ១ម៉ោងម្តង ប្រធានត្រូវត្រួតពិនិត្យក្នុងបន្ទប់សម្ងាត់អំពីសុវត្ថិភាព និងសណ្តាប់ធ្នាប់ សម្ភារ ដែលបំពាក់នៅទីនោះ ក្នុងករណីគ្មានអ្នកបោះឆ្នោតនៅក្នុងបន្ទប់សម្ងាត់។

ប្រធានត្រូវតាមដានពិនិត្យមើលដើម្បីឱ្យប្រាកដថា នៅពេលចេញពីបន្ទប់សម្ងាត់ អ្នកបោះឆ្នោតបានបត់សន្លឹកឆ្នោតតាមផ្នត់ដើមដូចការណែនាំ និងចាត់ចែងការងារតាមលំដាប់លំដោយដូចតទៅ៖

**សមាជិកទី២ ត្រូវ**

- *ចាត់ចែងសណ្តាប់ធ្នាប់អ្នកបោះឆ្នោតនៅបរិវេណខាងក្នុង។*
- *ជួយរកឈ្មោះ និងលេខរៀងអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត។*
- *ប្រសិនបើក្នុងប័ណ្ណព័ត៌មានអ្នកបោះឆ្នោតឃើញឈ្មោះនិងទីតាំងការិយាល័យផ្សេង ជម្រាបគាត់ឱ្យទៅកាន់ការិយាល័យបោះឆ្នោតនោះ ដើម្បីបោះឆ្នោត។*
- *ចេញក្រដាសលេខរៀងតាមលំដាប់មុនក្រោយ ក្នុងករណីចាំបាច់។*
- *ណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តកន្ទុយគ្នាជាជួរ។*
- *ប្រសិនបើការបោះឆ្នោតឈានដល់ម៉ោង ៣:០០នាទីរសៀលនៃថ្ងៃបោះឆ្នោត ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតទៀត អ្នកទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត។ ក្នុងករណីនេះ សមាជិកទី២ ត្រូវប្រកាសអញ្ជើញអ្នកបោះឆ្នោតដែលមានវត្តមាននៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ឱ្យចូលក្នុងជួរ និងត្រូវប្រមូលយក អ.ខ ឬ ឯ.អ ពីអ្នកបោះឆ្នោត ដែលនៅក្នុងជួរ ដោយចាប់ផ្តើមពីអ្នកបោះឆ្នោតដែលឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ឱ្យសមាជិកទី៣ នៅត្រង់មាត់ទ្វារ។*

សមាជិកទី៣ ត្រូវ

- ជម្រាបអ្នកបោះឆ្នោត ដែលកំពុងឈរជាជួរបន្តគ្នាតម្រង់ទៅកាន់មាត់ទ្វារចូលការិយាល័យបោះឆ្នោត អំពីអ្នកបោះឆ្នោតដែលត្រូវផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត។
- ផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោតមុនគេដល់អ្នកបោះឆ្នោតជាព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ ជនដែលមានពិការភាពមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជំនួយអមដំណើរជនដែលមានពិការភាពនោះ បន្ទាប់មកគឺអ្នកឈរមុខគេក្នុងជួរ។
- រំឭកអ្នកបោះឆ្នោតឱ្យរកមើលឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដែលបិទនៅមុខទីតាំងការិយាល័យបោះឆ្នោត៖
  - បើរកឃើញឈ្មោះ ត្រូវឱ្យគាត់ចាំលេខរៀង ដើម្បីជម្រាបជូនលេខាធិការ
  - បើរកមិនឃើញឈ្មោះ ត្រូវជម្រាបជូនសមាជិកទី ២ ដើម្បីជួយរកឈ្មោះ
- ឱ្យអ្នកបោះឆ្នោតបង្ហាញ អ.ខ ឬ ឯ.អ។
- ត្រួតពិនិត្យស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត។
- ចង្អុលបង្ហាញដល់អ្នកបោះឆ្នោត អំពីប័ណ្ណប្រកាសស្តីពីរបៀបគូសសន្លឹកឆ្នោត ដែលបិទនៅមាត់ទ្វារការិយាល័យបោះឆ្នោត។
- ជម្រាបអ្នកបោះឆ្នោតឱ្យដើរតម្រង់ទៅតុលេខាធិការ និងអនុប្រធាន។
- អនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលម្តង ១នាក់ និងមានវត្តមានក្នុងការិយាល័យបោះឆ្នោតចំនួន ៩នាក់ក្នុងពេលតែមួយ។
- ហៅឈ្មោះអ្នកបោះឆ្នោតម្នាក់ម្តងៗ រហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោតតាមលំដាប់លំដោយ នៅពេលការបោះឆ្នោតឈានចូលដល់ម៉ោង ៣:០០ នាទីរសៀល។

## សកម្មភាពនៅក្នុងការិយាល័យបោះឆ្នោត



*លេខាធិការ ត្រូវ*

- *សុំឱ្យអ្នកបោះឆ្នោតបង្ហាញ អ.ខ ឬ ឯ.អ របស់គាត់។*
- *ត្រួតពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថា គ្មានស្នាមទឹកខ្មៅលុបមិនជ្រះ។*
- *ពិនិត្យមើលលេខរៀងនៅលើប័ណ្ណព័ត៌មាន (បើមាន) ដើម្បីរកឈ្មោះអ្នកបោះឆ្នោត រួចប្រគល់ប័ណ្ណនេះជូនគាត់វិញ។*
- *សួរបញ្ជាក់ឈ្មោះ ពិនិត្យផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ របស់គាត់ជាមួយនឹងរូបពិត រួចពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងរូបថត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត។*
- *ដាក់បន្ទាត់តម្រង់តាមបណ្ដោយជួរឈ្មោះរបស់គាត់ និងគូសសញ្ញាធិកបញ្ជាក់ការបានមកបោះឆ្នោតរបស់គាត់ក្នុងកូនប្រអប់ទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះ។*
- *ណែនាំអ្នកបោះឆ្នោតឱ្យគូសសញ្ញាធិកនៅចុងឈ្មោះរបស់គាត់ក្នុងបញ្ជីបោះឆ្នោត។*
- *ហុច អ.ខ ឬ ឯ.អ របស់គាត់បន្តទៅឱ្យអនុប្រធាន ប្រសិនបើរូបថត ឈ្មោះ និងទិន្នន័យក្នុង អ.ខ ឬ ឯ.អ របស់អ្នកបោះឆ្នោតដូចគ្នានឹងរូបថត ឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត។*
- *ជម្រាបគាត់ឱ្យទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន។*

**លេខាធិការពិនិត្យរកមើលស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត**




**ចំណាំ៖**

- ប្រសិនបើពិនិត្យឃើញថា ម្រាមដៃអ្នកបោះឆ្នោតមានស្នាមប្រឡាក់ទឹកខ្មៅលុបមិនជ្រះ ឬរូបថត ឬ ឈ្មោះ និងទិន្នន័យមិនដូចគ្នា ត្រូវជូនគាត់ទៅជួបប្រធាន និងរាយការណ៍ពីករណីនេះ។
- ប្រសិនបើរកមិនឃើញមានឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ត្រូវជូនគាត់ទៅជួបប្រធាន និងរាយការណ៍។

| អនុប្រធាន ត្រូវ | |
|---|---|
| | - *ហែកសន្លឹកឆ្នោត ១សន្លឹក ចេញពីគល់បញ្ជីសន្លឹកឆ្នោត។*<br>- *បោះត្រាសម្ងាត់នៅផ្នែកខាងខ្នង និងបត់ជា ៨ផ្នត់ ហើយប្រគល់ជូនអ្នកបោះឆ្នោត រួមជាមួយ អ.ខ ឬ ឯ.អ របស់គាត់ផង។*<br>- *ណែនាំអ្នកបោះឆ្នោតថា៖*<br>▪ *នេះគឺជាសន្លឹកឆ្នោត។*<br>▪ *អ្នកត្រូវដើរទៅកាន់បន្ទប់សម្ងាត់ ប្រើប៊ិកដែលមាននៅទីនោះស្រាប់ ឬប៊ិកផ្ទាល់ខ្លួន (លើកលែងតែខ្មៅដៃ) គូសសញ្ញាគាំទ្រមួយនៅក្នុងប្រឡោះបួនជ្រុងទ្រវែងនៃគណបក្សនយោបាយតែ ១គត់ដែលអ្នកពេញចិត្ត ដោយគូសសញ្ញាដូចក្នុងប័ណ្ណប្រកាសដែលបិទជាប់នឹងបន្ទប់សម្ងាត់នេះ។*<br>▪ *ពិចារណាឱ្យហ្មត់ចត់មុននឹងគូសសញ្ញាគាំទ្រ ដើម្បីបង្ការការខូចសន្លឹកឆ្នោត ដោយសារការប្ដូរចិត្ត។*<br>▪ *មុននឹងចេញពីបន្ទប់សម្ងាត់ អ្នកត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលអ្នកបានគូសស្ថិតនៅក្នុងផ្នត់ មិនអាចមើលឃើញ និងឱ្យរូបសញ្ញានៃត្រាសម្ងាត់ស្ថិតនៅខាងក្រៅ។*<br>▪ *ដើរទៅកាន់តុដាក់ហិបឆ្នោត លើកសន្លឹកឆ្នោតដែលបត់រួចហើយ និងមានត្រាសម្ងាត់នៅខាងខ្នងបង្ហាញសមាជិកទី១ ដែលនៅក្បែរនោះ រួចស៊កសន្លឹកឆ្នោតតាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត។*<br>- *ផ្ដល់សន្លឹកឆ្នោត ១សន្លឹកថ្មីទៀត តាមការអនុញ្ញាតពីប្រធាន ចំពោះអ្នកបោះឆ្នោតដែលបានធ្វើឱ្យខូច ឬហែកដោយអចេតនា ឬត្រូវប្ដូរចិត្ត។* |

**ចំណាំ៖**

- អនុប្រធានមិនត្រូវប្រគល់សន្លឹកឆ្នោត និងអនុញ្ញាតឱ្យអ្នកបោះឆ្នោតបន្ទាប់ចូលក្នុងបន្ទប់សម្ងាត់ទេ ប្រសិនបើអ្នកបោះឆ្នោតមុនមិនទាន់ចេញផុតពីបន្ទប់សម្ងាត់។
- ការបោះត្រាសម្ងាត់នៅផ្នែកខាងខ្នងនៃសន្លឹកឆ្នោតនីមួយៗ មិនត្រូវយកសៀវភៅសន្លឹកឆ្នោតធ្វើជាទ្រនាប់ និងបត់សន្លឹកឆ្នោតឡើយ ដើម្បីបង្ការការប្រឡាក់ទឹកត្រាលើសន្លឹកឆ្នោតផ្សេងទៀត។

**អនុប្រធានបង្ហាញរបៀបបត់សន្លឹកឆ្នោតឱ្យបាន ៨ផ្នត់ មុននឹងហុចឱ្យអ្នកបោះឆ្នោត**



**របៀបបត់សន្លឹកឆ្នោតឱ្យបាន ៨ផ្នត់ ដើម្បីឱ្យរូបសញ្ញាត្រាសម្ងាត់ស្ថិតនៅខាងក្រៅ**



| សមាជិកទី១ ត្រូវ | |
|---|---|
| | - *ឱ្យអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោតដែលបានបត់រួចនោះ ដោយដាក់បែរផ្នែកខាងខ្នងដែលមានបោះត្រាសម្ងាត់ទៅរកគាត់ ហើយស៊កវាដោយខ្លួនឯងតាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត។*<br>- *ពិនិត្យឱ្យប្រាកដថា ពិតជាសន្លឹកឆ្នោតផ្លូវការតែ ១សន្លឹក ដែលមានបោះត្រាសម្ងាត់ជាផ្លូវការ សម្រាប់ការិយាល័យបោះឆ្នោតនោះ ស្របពេលដែលអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោតដែលបានបត់រួចបម្រុងនឹងស៊កទៅក្នុងហិបឆ្នោត។*<br>- *ជូត និងជ្រលក់ម្រាមចង្អុលដៃស្តាំ ឬម្រាមផ្សេងទៀត (ប្រសិនបើម្រាមចង្អុលដៃស្តាំពិការ) របស់អ្នកបោះឆ្នោតដែលបានបោះឆ្នោតរួច ចូលទៅក្នុងដបទឹកខ្មៅលុបមិនជ្រះឱ្យលិចគល់ក្រចក និងឱ្យគាត់រង់ចាំឱ្យស្ងួតបន្តិចប្រមាណ ៣០វិនាទី ទើបអនុញ្ញាតឱ្យគាត់ចេញពីការិយាល័យបោះឆ្នោត។*<br>- *បិទគម្របដបទឹកខ្មៅលុបមិនជ្រះឱ្យជិត ប្រសិនបើគ្មានអ្នកបោះឆ្នោតមួយរយៈពេលយូរគួរសម ដើម្បីការពារកុំឱ្យវាហួត និងក្រឡុកវារាល់ ៣០នាទីម្តង។*<br>- *បម្រុងទុកទឹកខ្មៅលុបមិនជ្រះ ១ដបទៀត សម្រាប់ប្រើនៅពេលអស់ទឹកខ្មៅដបទី១។* |

ការជ្រលក់ម្រាមចង្អុលដៃស្តាំរបស់អ្នកបោះឆ្នោតទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ



**ចំណាំ៖**

សមាជិកទី១ ត្រូវ៖

- ច្នៃប្រឌិតរកកំប៉ុង ឬដបជ័រ ដោយកាត់ឱ្យខ្លី ដាក់ដីខ្សាច់ សម្រាប់ដាក់ទប់ដបទឹកខ្មៅលុបមិនជ្រះ។
- រាយការណ៍ជាបន្ទាន់ជូនប្រធាន គ.ក.ប ប្រសិនបើចាប់ភស្តុតាងបានថា មានអ្នកបោះឆ្នោតណាម្នាក់បានស៊ក ឬមានបំណងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពី ១សន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត។
- បិទភ្ជិតសន្ទះប្រឡោះស៊កសន្លឹកឆ្នោតជាបណ្តោះអាសន្ន ប្រសិនបើគ្មានអ្នកបោះឆ្នោតមកបោះឆ្នោត និងត្រូវបើកសន្ទះវិញនៅពេលមានវត្តមានអ្នកបោះឆ្នោត។

៦. ការងាររបស់ប្រធាន គ.ក.ប ក្នុងពេលមានករណីផ្សេងៗកើតឡើងនៅពេលបោះឆ្នោត

ក. ករណីអ្នកបោះឆ្នោតមានស្រាមដៃប្រឡាក់ស្នាមទឹកខ្មៅលុបមិនជ្រះ ឬរូបថតមិនដូចគ្នា ឈ្មោះ ឬទិន្នន័យមិនដូចគ្នា

ករណីនេះ លេខាធិការ ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន។

*ប្រធាន គ.ក.ប ត្រូវ*

- *អញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យមកធ្វើការកត់សម្គាល់អំពីបញ្ហានេះ។*
- *ឱ្យអ្នកបោះឆ្នោតនោះពន្យល់អំពីបញ្ហានោះ ប្រសិនបើអ្នកបោះឆ្នោតមិនអាចផ្ដល់ការពន្យល់របស់ខ្លួនបានសមហេតុផល នោះគាត់នឹងត្រូវសន្និដ្ឋានថា មានបំណងបោះឆ្នោតលើសពី ១ដង ឬមានចេតនាទុច្ចរិតក្នុងការបោះឆ្នោត ដែលត្រូវមានទោសតាមច្បាប់។*
- *ដកហូត អ.ខ ឬ ឯ.អ របស់គាត់ជាបណ្ដោះអាសន្ន ហើយបញ្ជូនទៅ គឃ.សប ដើម្បីចាត់វិធានការបន្ត។*
- *ចាត់លេខាធិការឱ្យកត់ត្រាទុកអំពីហេតុការណ៍នេះ នៅក្នុង ទ.១១០១ និងត្រូវស្រង់ឈ្មោះ និងទិន្នន័យពី អ.ខ ឬ ឯ.អ របស់ជននោះសម្រាប់ការតាមដានបន្ថែមទៀត។*
- *ប្រសិនបើគាត់មិនយល់ព្រមតាមការអនុវត្តនីតិវិធីខាងលើ ប្រធាន គ.ក.ប ឬ គឃ.សប ត្រូវស្នើសុំអាជ្ញាធរមានសមត្ថកិច្ចឱ្យឃាត់ខ្លួនជននោះរហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់។*

ខ. ករណីលេខាធិការរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតមិនឃើញ

ករណីនេះ លេខាធិការត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន។

*ប្រធាន គ.ក.ប ត្រូវ*

- *ជម្រាបអ្នកបោះឆ្នោតថា គាត់មិនអាចបោះឆ្នោតបានឡើយ ពីព្រោះគាត់គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យនេះ។*
- *សួររកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតរបស់គាត់ ដើម្បីផ្ទៀងផ្ទាត់ និងត្រូវណែនាំគាត់អំពីទីតាំងការិយាល័យបោះឆ្នោតណាមួយក្នុងឃុំសង្កាត់ដែលឈ្មោះរបស់គាត់មានក្នុងបញ្ជីបោះឆ្នោត។*
- *ជម្រាបគាត់ឱ្យចេញពីការិយាល័យបោះឆ្នោត។*

គ. ករណីអ្នកបោះឆ្នោតណាម្នាក់មានបំណងសឹកសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពី ១សន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញពីការិយាល័យបោះឆ្នោត

- ចំពោះអ្នកបោះឆ្នោតដែលមិនមែនជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *- ប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត មុននឹងចាត់វិធានការឆែកឆេររកសន្លឹកឆ្នោតផ្លូវការ។*<br>*- ឃាត់អ្នកបោះឆ្នោតមិនឱ្យបោះឆ្នោត។*<br>*- ដកហូតសន្លឹកឆ្នោតមិនត្រឹមត្រូវទាំងនោះ និងឆែកឆេររកសន្លឹកឆ្នោតផ្លូវការ (បើមាន) ដាក់ក្នុងស្រោមសំបុត្រមានកាខ្វងថា «សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត»។*<br>*- ដកហូត អ.ខ ឬ ឯ.អ របស់ជននោះជាបណ្ដោះអាសន្ន។*<br>*- ចាត់ចែងធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្ដឹងចោទប្រកាន់ទៅ គឃ.សប។* |

- ប្រសិនបើជនដែលបានប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយបើមានភស្តុតាងគ្រប់គ្រាន់នោះ គឃ.សប ត្រូវបន្តប្ដឹងទៅ គជ.ខប និង គ.ជ.ប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

**ឃ. ករណីអ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង**

អ្នកបោះឆ្នោតជាជនមានពិការភាព ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង អាចស្នើសុំអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬអាចស្នើសុំជំនួយពីប្រធាន គ.ក.ប។ ប្រធាន គ.ក.ប ត្រូវអមដំណើរអ្នកបោះឆ្នោតជាជនដែលមានពិការភាពនោះ ឬអាចចាត់សមាជិក គ.ក.ប ណាម្នាក់ជួយក៏បាន ប៉ុន្តែត្រូវមានការយល់ព្រមពីសាមីខ្លួន។

- ប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយដែលជួយអ្នកបោះឆ្នោតដែលមានពិការភាព ត្រូវសួរអ្នកបោះឆ្នោតជាជនមានពិការភាពនោះថា តើគាត់បោះឆ្នោតឱ្យគណបក្សនយោបាយមួយណា ដោយសួរតិចៗធ្វើយ៉ាងណាកុំឱ្យអ្នកដែលនៅក្នុងការិយាល័យបោះឆ្នោតឮឱ្យសោះ។
- ប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយ ត្រូវគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ដែលឆ្លើយតបនឹងការជ្រើសរើសរបស់អ្នកបោះឆ្នោតជាជនមានពិការភាព ហើយបត់សន្លឹកឆ្នោតនោះតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅក្នុងផ្នត់ រួចត្រូវនាំអ្នកបោះឆ្នោតទៅកាន់ហិបឆ្នោត និងជួយស៊កសន្លឹកឆ្នោតរបស់គាត់តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត។
- ប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយដែលជួយអ្នកបោះឆ្នោតមានពិការភាព ត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់។

**ង. ករណីអ្នកបោះឆ្នោតជាជនពិការភ្នែកទាំងសងខាង ហើយមានបំណងចង់បោះឆ្នោតដោយខ្លួនឯង**

ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាងនោះឱ្យទៅជួបលេខាធិការ ដើម្បីបង្ហាញ អ.ខ ឬ ឯ.អ របស់ខ្លួន ដូចអ្នកបោះឆ្នោតដែលមិនមានពិការភាពដែរ។ នៅពេលអនុវត្តចំណុចនេះរួចរាល់ លេខាធិការត្រូវហុច អ.ខ ឬ ឯ.អ ជូនអនុប្រធាន គ.ក.ប។

| | |
|---|---|
| *អនុប្រធាន គ.ក.ប ត្រូវ* | *- ហែកសន្លឹកឆ្នោត ១សន្លឹក ចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង បត់ជា ៤ផ្នត់ និងត្រូវណែនាំអ្នកពិការឱ្យស្ទាបសន្លឹកឆ្នោត និងស្ទាមបត់ រួចលាសន្លឹកឆ្នោតឱ្យស្មើឡើងវិញ និងដាក់នៅក្នុងក្របក្រដាសពិសេស ដោយឱ្យផ្នែកខាងមុខនៃសន្លឹកឆ្នោតលេចចេញប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សតាមប្រហោងសម្រាប់គូស និងប្រើឃ្នាបគាបសន្លឹកឆ្នោតនោះភ្ជាប់នឹងក្របក្រដាសពិសេស ដើម្បីបង្ការកុំឱ្យប្រអប់លេខរៀងសម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយ ងាក ឬល្អៀងចេញពីប្រហោងនៃក្របក្រដាសពិសេស។*<br>*- ប្រគល់ក្របក្រដាសពិសេសដែលមានដាក់សន្លឹកឆ្នោតខាងក្នុងជូនទៅអ្នកបោះឆ្នោតដែលពិការភ្នែកទាំងសងខាង និងកាន់ម្រាមដៃណាមួយរបស់គាត់ឱ្យមកប៉ះ និងស្ទាបប្រហោងរាងបួនជ្រុងទ្រវែង និងរាងមូលតូចដែលចោះលើក្របក្រដាសពិសេសពីលើចុះក្រោម និងជម្រាបគាត់ថា៖*<br>*▪ អ្នកអាចស្ទាប និងរាប់ប្រហោងរាងបួនជ្រុងទ្រវែង និងរាងមូលតូចដែលកំណត់លេខរៀង និងចំនួនគណបក្សនយោបាយទាំងអស់នៅលើសន្លឹកឆ្នោត។ ប្រហោងរាងបួនជ្រុងទ្រវែង គឺជាប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធ។ ឯប្រហោងរាងមូលតូច គឺកំណត់សម្គាល់គណបក្សនយោបាយ ដែលពុំបានឈរឈ្មោះក្នុងមណ្ឌលពាក់ព័ន្ធ។*<br>*▪ អ្នកត្រូវចងចាំអំពីលេខរៀងរបស់គណបក្សនយោបាយដែលខ្លួនពេញចិត្ត។*<br>*▪ អ្នកត្រូវប្រើប៊ិកគូសសញ្ញាគាំទ្រក្នុងប្រហោងរាងបួនជ្រុងទ្រវែង បន្ទាប់ពីអ្នកបានស្ទាប និងដឹងច្បាស់អំពីប្រអប់លេខរៀងគណបក្ស ដែលអ្នកពេញចិត្ត ។*<br>*▪ អ្នកត្រូវដោះឃ្នាប និងដកសន្លឹកឆ្នោតចេញពីក្របក្រដាសពិសេស រួចបត់តាមផ្នត់ដើម ហើយស្នើសុំប្រធាន គ.ក.ប ឱ្យជួយជូនទៅស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោត។* |
| *ប្រធាន គ.ក.ប ត្រូវ* | *- ជួយជូនអ្នកបោះឆ្នោតជាជនពិការភ្នែកទាំងសងខាងនោះទៅកាន់បន្ទប់សម្ងាត់ និងជួយរកប៊ិកសម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយ។*<br>*- ជួយរៀបចំក្របក្រដាសពិសេស ឱ្យមានភាពត្រឹមត្រូវ ប្រសិនបើពិនិត្យឃើញថា ក្របក្រដាសពិសេសនោះមានសភាពមិនប្រក្រតី ឬដាក់មិនទំនង។*<br>*- ចេញពីបន្ទប់សម្ងាត់ និងរង់ចាំជួយបន្ថែមទៀត ប្រសិនបើមានសំណូមពរពីអ្នកបោះឆ្នោតនោះ។* |

**ចំណាំ៖**

រាល់ការអនុវត្តនីតិវិធីខាងលើនេះ ត្រូវធ្វើឡើងចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ។

ច. ករណីអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប៉ុនប៉ងចង់ឃើញការគូសសញ្ញានៅលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោត

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *- ព្រមានជននោះផ្ទាល់មាត់ ចំពោះការប៉ុនប៉ងលើកទី១។*<br>*- ចាត់ទុកជាការរំលោភលើគោលការណ៍សម្ងាត់នៃការបោះឆ្នោត ហើយជនដែលពាក់ព័ន្ធត្រូវតែបណ្តេញចេញពីការិយាល័យបោះឆ្នោត និងត្រូវទទួលទោសតាម ច.ប.ត.រ ចំពោះការប៉ុនប៉ងជាលើកទី២។*<br>*- ចាត់លេខាធិការឱ្យកត់ត្រាហេតុការណ៍ទាំងនេះក្នុងកំណត់ហេតុមួយដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត។*<br>*- បញ្ជូនកំណត់ហេតុស្តីពីហេតុការណ៍នោះទៅ គឃ.សប ក្នុងករណីជនប្រព្រឹត្តល្មើសលើគោលការណ៍សម្ងាត់នៃការបោះឆ្នោតនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត។* |

ឆ. ករណីអ្នកបោះឆ្នោតធ្វើឱ្យខូចសន្លឹកឆ្នោត ឬធ្វើឱ្យរហែក ឬធ្វើឱ្យប្រឡាក់ដោយអចេតនា ឬដែលបានគូសសញ្ញាលើសន្លឹកឆ្នោតរួចហើយ តែបានប្តូរចិត្តវិញ

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *- អនុញ្ញាតឱ្យអនុប្រធានផ្តល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោត ១ សន្លឹកផ្សេងទៀត ហើយផ្តល់ឱ្យតែ ១លើកគត់។*<br>*- ប្រាប់អ្នកបោះឆ្នោតដែលស្នើសុំសន្លឹកឆ្នោត ១សន្លឹកផ្សេងទៀត ឱ្យបត់សន្លឹកឆ្នោតខូចតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅខាងក្នុងផ្នត់ រួចប្រគល់ជូនគាត់។*<br>*- ស៊កសន្លឹកឆ្នោតដែលខូចនោះ ទៅក្នុងស្រោមសំបុត្រ១ ដែលមានកាខ្នងស្រាប់ថា «សន្លឹកឆ្នោតខូច»។*<br>*- អាចសម្រេចមិនព្រមផ្តល់សន្លឹកឆ្នោត ១សន្លឹកផ្សេងទៀត តាមការស្នើសុំ ប្រសិនបើមានអ្នកបោះឆ្នោតមួយចំនួនមកសុំបន្តបន្ទាប់គ្នាដែលអាចចាត់ទុកថាជាភាពមិនប្រក្រតីមួយនោះ ហើយឱ្យលេខាធិការកត់ត្រាករណីទាំងនោះចូលក្នុង ទ.១១០១។*<br>*- រំឭកអនុប្រធានឱ្យណែនាំអ្នកបោះឆ្នោតបន្ទាប់ អំពីរបៀបបង្ការសន្លឹកឆ្នោតខូច។*<br>*- ធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់ សម្រាប់ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត។* |

**ចំណាំ៖**

ប្រធាន គ.ក.ប ត្រូវដឹងច្បាស់ពីចំនួនសន្លឹកឆ្នោតលើសពីចំនួនអ្នកបោះឆ្នោតនៅក្នុងការិយាល័យរបស់ខ្លួន ហើយត្រូវយកចិត្តទុកដាក់អំពីបាតុភាពនៃការសុំប្តូរសន្លឹកឆ្នោតជាបន្តបន្ទាប់។

ជ. ករណីមានការជំទាស់ ឬការតវ៉ាពីភ្នាក់ងារគណបក្សនយោបាយណាម្នាក់ក្នុងពេលបោះឆ្នោត

| | |
|---|---|
| ប្រធាន គ.ក.ប ត្រូវ | *- ឱ្យភ្នាក់ងារគណបក្សនយោបាយលើកការជំទាស់ ឬការតវ៉ានោះមកខ្លួនផ្ទាល់។*<br>*- ឱ្យបង្ហាញពីមូលហេតុ ឬភស្តុតាងដែលនាំឱ្យគាត់ជឿថាមានភាពមិនប្រក្រតី ឬមានការរំលោភលើ ច.ប.ត.រ ឬ ប.ន.ត.រ។* |

- ប្រសិនបើការជំទាស់ ឬការតវ៉ាសមហេតុផល

| | |
|---|---|
| ប្រធាន គ.ក.ប ត្រូវ | *- បញ្ឈប់ជាបណ្ដោះអាសន្ននូវកិច្ចប្រតិបត្តិការបោះឆ្នោត។*<br>*- ស្ដាប់ការជំទាស់ ឬការតវ៉ានោះ។*<br>*- ពិភាក្សាជាមួយសមាជិក គ.ក.ប ដទៃទៀត។*<br>*- សម្រេចយល់ព្រម ឬបដិសេធការជំទាស់ ឬការតវ៉ានោះ។* |

- ប្រសិនបើយល់ព្រមតាមការជំទាស់ ឬការតវ៉ានោះ ប្រធានត្រូវណែនាំ និងរំឭកសមាជិក គ.ក.ប និងអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតអំពីខ្លឹមសារពាក់ព័ន្ធដែលមានចែងក្នុង ច.ប.ត.រ និង ប.ន.ត.រ ហើយត្រូវចាត់វិធានការដោះស្រាយភាពមិនប្រក្រតីនោះជាបន្ទាន់។
- ប្រសិនបើបដិសេធការជំទាស់ ឬការតវ៉ា ប្រធានត្រូវ៖
  - ផ្ដល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធនោះជូនភ្នាក់ងារគណបក្សនយោបាយ។ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនៅតែជំទាស់ ឬតវ៉ា ប្រធាន គ.ក.ប ត្រូវកត់ត្រាករណីជំទាស់ ឬតវ៉ានេះទៅក្នុង ទ.១១០១ ដោយឱ្យអ្នកជំទាស់ ឬតវ៉ានោះចុះហត្ថលេខាជាមួយ។ ប្រសិនបើគាត់មិនយល់ព្រមចុះហត្ថលេខា ករណីនៃការជំទាស់ ឬការតវ៉ានោះមិនត្រូវបានកត់ត្រាក្នុងកំណត់ហេតុទេ។
  - ជម្រាបជូនភ្នាក់ងារគណបក្សនយោបាយថា គាត់អាចបន្តប្ដឹងជំទាស់ ឬតវ៉ាទៅ គឃ.សប អំពីករណីនេះ ប៉ុន្តែក្នុងស្ថានភាពនេះ ត្រូវយល់ព្រមទទួលយកវិធានការរបស់ គ.ក.ប និងមិនត្រូវរំខាន ឬជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត ហើយប្រធានត្រូវប្រកាសបន្តដំណើរការបោះឆ្នោតតទៅទៀត។
  - ផ្ដល់ ទ.១២០២ ជូនគាត់សម្រាប់ប្ដឹងទៅ គឃ.សប (ប្រសិនបើគាត់ស្នើសុំ)។

ឈ. ករណីមានអ្នកបោះឆ្នោតណាម្នាក់រំខានដល់កិច្ចប្រតិបត្តិការបោះឆ្នោត ទោះបីគាត់ស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬកំពុងឈរតម្រង់ជួរនៅខាងក្រៅការិយាល័យក្ដី

| | |
|---|---|
| ប្រធាន គ.ក.ប ត្រូវ | *- ណែនាំឱ្យគាត់រក្សារបៀបរៀបរយ។*<br>*- ស្នើកម្លាំងសន្តិសុខឱ្យបណ្ដេញបុគ្គលនោះចេញ ឬឃាត់ខ្លួនបុគ្គលនោះរហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ក្នុងករណីអ្នកបោះឆ្នោតនោះបដិសេធមិនព្រមគោរពតាមបញ្ជារបស់ខ្លួន។* |

**ញ. ករណីកិច្ចប្រតិបត្តិការបោះឆ្នោតត្រូវបានរំខានដល់កម្រិតដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោតបន្តទៀតបាន**

ប្រធាន គ.ក.ប អាចស្នើសុំកម្លាំងសន្តិសុខឱ្យរៀបចំសាឡើងវិញនូវរបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោត ប្រសិនបើកិច្ចប្រតិបត្តិការបោះឆ្នោតត្រូវបានរំខានដល់កម្រិត ដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោតបន្តទៀតបាន ឬធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរី។

សកម្មភាពរំខានដល់កម្រិតមិនអាចបោះឆ្នោតបានមាន៖

- ការបញ្ចេញសម្រែកខ្លាំងៗ ឬការបញ្ចេញសម្តីគំរាមកំហែង ឬជេរប្រមាថមាក់ងាយ។
- ការធ្វើសកម្មភាពរារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ការរុញច្រានដោយប្រើកម្លាំងធ្ងន់។
- ការគប់វត្ថុផ្សេងៗ សំដៅអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត។
- ការអុកឡុកនៃបុគ្គលណាម្នាក់ ឬច្រើននាក់ដែលធ្វើឱ្យរំខានដល់អ្នកបោះឆ្នោត។
- ការបញ្ចេញអាកប្បកិរិយា និងភាសាមិនសមរម្យ។
- ការបញ្ចេញឱ្យឃើញនូវអាវុធ គ្រឿងផ្ទុះ ឬសារធាតុផ្សេងៗប្រកបដោយគ្រោះថ្នាក់។

**ដ. ករណីការបោះឆ្នោតឈានដល់ពេលបញ្ចប់នៅម៉ោង ៣:០០ នាទីរសៀល ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត**

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *- ចាត់សមាជិកទី២ ឱ្យដើរប្រមូល អ.ខ ឬ ឯ.អ ពីអ្នកបោះឆ្នោត ដែលកំពុងឈរក្នុងជួរ ដោយចាប់ផ្តើមប្រមូលពីអ្នកឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ជូនសមាជិកទី៣។*<br>*- ចាត់សមាជិកទី៣ ឱ្យហៅឈ្មោះម្នាក់ម្តងៗ រហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ បានចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោត។* |

**ចំណាំ៖**

- មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ ចំពោះអ្នកបោះឆ្នោតដែលគ្មានវត្តមាននៅខាងក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតនៅនាទីចុងក្រោយនាម៉ោង ៣:០០ នាទីរសៀលនៃថ្ងៃបោះឆ្នោតទេនោះ។
- ប្រធាន គ.ក.ប មិនអាចបិទការបោះឆ្នោតនៅការិយាល័យរបស់ខ្លួននៅមុនម៉ោង ៣:០០ នាទីរសៀលនៃថ្ងៃបោះឆ្នោតបានឡើយ ប្រសិនបើអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនទាន់បានបោះឆ្នោតគ្រប់គ្នាទេ ទោះបីគ្មានអ្នកបោះឆ្នោតឈររង់ចាំបោះឆ្នោតក្តី។
- ប្រធាន គ.ក.ប អាចប្រកាសបញ្ចប់ការបោះឆ្នោតនៅការិយាល័យរបស់ខ្លួននៅមុនម៉ោង ៣:០០ នាទីរសៀលបាន ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានមកបោះឆ្នោតគ្រប់គ្នាហើយ។

## ៧. ការបិទការិយាល័យបោះឆ្នោតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន

មុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត ប្រសិនបើការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួនស្ថិតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត គ.ជ.ប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតនោះ ឬទាំងនោះបាន។

ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន អាចជាករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម ៖

- ការរញ្ជួយផែនដី ទឹកជំនន់ ភាពរាំងស្ងួត អគ្គិភ័យ ឬមហាអគ្គិភ័យ ភាពក្តៅខ្លាំង ខ្យល់ព្យុះ ជំងឺរាតត្បាត។
- សង្គ្រាម សង្គ្រាមស៊ីវិល ការបះបោរ។
- ការដួលរលំអគារសម្រាប់បម្រើការបោះឆ្នោត ដោយយថាហេតុណាមួយ ឬការខូចខាតប្រហាក់ប្រហែលគ្នាដែលនាំឱ្យមានគ្រោះថ្នាក់។
- ការរាំងស្ទះផ្នែករដ្ឋបាលដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន។

### ក. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន កើតមាននៅមុនថ្ងៃបោះឆ្នោត

ប្រធាន គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់អំពីស្ថានភាពជាក់ស្តែងទៅ គឃ.សប។

### ខ. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន កើតមាននៅក្នុងថ្ងៃបោះឆ្នោត នៅមុនពេល ឬក្នុងពេលដំណើរការបោះឆ្នោត

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *-មានសិទ្ធិសម្រេចមិនបើក ឬអាចបិទការិយាល័យបោះឆ្នោត។*<br>*- រាយការណ៍ជាបន្ទាន់អំពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតជូន គឃ.សប ដើម្បី គឃ.សប រាយការណ៍បន្តទៅ គធ.ខប និងដើម្បី គធ.ខប រាយការណ៍ជាបន្ទាន់ជូន គ.ជ.ប។* |

**ចំណាំ៖**

ការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬដែលត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ត្រូវតែបិទរហូតពេញមួយថ្ងៃ។

### គ. ករណីមានការិយាល័យបោះឆ្នោតមិនត្រូវបានបើក ឬត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *- វេចខ្ចប់ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង សន្លឹកឆ្នោតមិនទាន់ប្រើ ព្រមទាំងប្រមូលសម្ភារ ឧបករណ៍ និងឯកសារពាក់ព័ន្ធផ្សេងទៀតសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត ដោយបំពេញ ទ.១១០៧ រួចបញ្ជូនយកមករក្សាទុកនៅ គឃ.សប ។*<br>*- ធ្វើកំណត់ហេតុស្តីពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតបញ្ជូនយកមករក្សាទុកនៅ គឃ.សប រួមជាមួយសម្ភារឯកសារបោះឆ្នោត។* |

**ប្រធាន គ.ក.ប ត្រូវ**

- កំណត់សន្លឹកឆ្នោតដែលបានបោះរួចនៅក្នុងហិប ទុកជាមោឃៈ ដោយមិនត្រូវរាប់បញ្ចូលជាលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ឡើយ។
- ជូនដំណឹងដល់សមាសភាព គ.ក.ប នៃការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬបានបិទថា គ.ក.ប នេះ ត្រូវរំសាយ និងទទួលប្រាក់កម្រៃស្របតាមកិច្ចសន្យា។

ឃ. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន កើតមានឡើងនៅក្រោយពេលបិទការបោះឆ្នោត ដែលពេលនោះ ទ.១១០១ ត្រូវបានធ្វើរួចរាល់ ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចហើយនៅខាងក្នុង រួមទាំងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅរក្សាបានល្អ

ប្រធាន គ.ក.ប ត្រូវបញ្ជូនសម្ភារ ឯកសារទាំងនោះទៅ គឃ.សប ដើម្បីចាត់ចែងការរាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គឃ.សប ឬទីតាំងសុវត្ថិភាពណាមួយ។

**ប្រធាន គ.ក.ប ត្រូវ**

- វេចខ្ចប់កញ្ចប់សុវត្ថិភាព «ក» តែមិនចាំបាច់បិទការសុវត្ថិភាពទេ ដាក់ក្នុងស្បោង «ខ» រួចចាក់សោឃ្លុំមានលេខ។
- វេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ដោយឡែក។
- បំពេញលិខិតបញ្ជូន និងប្រគល់ ទទួល (ទ.១១០៧) ចំនួន ២ច្បាប់ ប្រើពេលប្រគល់ ទទួល ក្នុងនោះ គឃ.សប រក្សាទុក ១ច្បាប់ និង គ.ក.ប រក្សាទុក ១ច្បាប់។
- បញ្ជូន និងប្រគល់ហិបឆ្នោត ស្បោង «ខ» និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ គឃ.សប។ ក្នុងការបញ្ជូនត្រូវមានការអមដំណើរដោយអនុប្រធាន និងមន្ត្រី គ.ក.ប មួយចំនួន ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងកម្លាំងសន្តិសុខ ២ នាក់ផង។

ង. ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន កើតមានឡើងនៅក្រោយពេលបិទការបោះឆ្នោត ហើយ ទ.១១០១ ត្រូវបានធ្វើរួចរាល់ ប៉ុន្តែហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចហើយនៅខាងក្នុង រួមទាំងសម្ភារ ឯកសារ ត្រូវបានបំផ្លាញ ឬខូច

ប្រធាន គ.ក.ប ត្រូវបញ្ជូនសម្ភារ ឯកសារទាំងនោះទៅរក្សាទុកនៅទីស្នាក់ការ គឃ.សប។

**ប្រធាន គ.ក.ប ត្រូវ**

- ធ្វើរបាយការណ៍ពីសភាពការណ៍ជាក់ស្តែងជូន គឃ.សប។
- ប្រមូល និងវេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតដែលនៅសល់អមដោយរបាយការណ៍ជូន គឃ.សប។
- បំពេញ ទ.១១០៧ ចំនួន ២ច្បាប់ ប្រើពេលប្រគល់ ទទួល ក្នុងនោះគឃ.សបរក្សាទុក១ច្បាប់ និងគ.ក.បរក្សាទុក១ច្បាប់។

## V. ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត

នៅពេលអ្នកបោះឆ្នោតចុងក្រោយបង្អស់បានបោះឆ្នោតរួច និងបានចេញផុតពីការិយាល័យបោះឆ្នោតប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី៣ ឱ្យចាត់វិធានការចាំបាច់ ដើម្បីការពារច្រកចូលការិយាល័យបោះឆ្នោត កុំឱ្យអ្នកគ្មានភារកិច្ចចេញចូល។ បន្ទាប់មក ប្រធាន គ.ក.ប ត្រូវប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ និងអនុវត្តការងារជាបន្តបន្ទាប់ដូចតទៅ៖

*ប្រធាន គ.ក.ប ត្រូវ*

- *បិទភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំង២ នៃហិបឆ្នោត។*
- *បិទក្រដាសស្តើង ១សន្លឹក ដែលមានចុះហត្ថលេខារបស់គាត់ និងភ្នាក់ងារគណបក្សនយោបាយ ពាសពីលើសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំង២ នោះ។*
- *បិទគម្របខាងក្រៅនៃហិបឆ្នោត និងចាក់សោឃ្លុំមានលេខនៅត្រង់ក្រវិលសម្រាប់ចាក់សោទាំង២ នៃហិបឆ្នោត រួចអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោត និងសោឃ្លុំមានលេខទាំង២ នោះ។*
- *ចាត់លេខាធិការ ឱ្យកត់ត្រាបន្ថែមក្នុង ទ.១១០១ នូវពេលវេលានៃការបិទការបោះឆ្នោត ព្រមទាំងលក្ខណៈសម្គាល់ និងលេខនៃសោឃ្លុំទាំង២។*
- *ចាត់វិធានការការពារហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុងយ៉ាងហ្មត់ចត់។*

**ចំណាំ៖** ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អាចថតយកសកម្មភាពនៅការិយាល័យបោះឆ្នោត ក្រោយពីការប្រកាសបិទការបោះឆ្នោត ដោយសុំការអនុញ្ញាតពីប្រធាន គ.ក.ប។

### ១. ការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច (បើមាន)

*ប្រធាន គ.ក.ប ត្រូវ*

- *ចាត់លេខាធិការឱ្យរាប់ ចំនួនគំនូសសញ្ញាក្នុងកូនប្រអប់ផ្នែកខាងដើមនៅក្នុងបញ្ជីបោះឆ្នោត និងរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានមកបោះឆ្នោត។*
- *ឱ្យអនុប្រធានកត់សម្គាល់រវាងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ និងគល់បញ្ជីនៃសន្លឹកឆ្នោតមិនបានប្រើ រួចរាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងសន្លឹកឆ្នោតខូច ដោយឡែកពីគ្នា។*
- *ឱ្យលេខាធិការ និងអនុប្រធានធ្វើការផ្ទៀងផ្ទាត់គ្នា ប្រសិនបើឃើញថា ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានមកបោះឆ្នោត លេខាធិការត្រូវកត់ត្រាតួលេខចំនួនទាំងនេះក្នុង ទ.១១០១។*

ប្រសិនបើការផ្ទៀងផ្ទាត់នេះបង្ហាញថា មានភាពខុសគ្នារវាងចំនួនសន្លឹកឆ្នោតដែលបានប្រើ និងចំនួនអ្នកបានមកបោះឆ្នោត៖

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *- ឱ្យលេខាធិការផ្ទៀងផ្ទាត់ជាលើកទី២ នូវចំនួនអ្នកបោះឆ្នោតដែលបានមកបោះឆ្នោត នៅលើបញ្ជីបោះឆ្នោត។*<br>*- ឱ្យអនុប្រធានផ្ទៀងផ្ទាត់ឡើងវិញដែរ នូវចំនួនសន្លឹកឆ្នោតដែលបានប្រើ (រាប់ចំនួនសន្លឹកគល់បញ្ជីនៃសន្លឹកឆ្នោតដែលបានប្រើ) ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច។*<br>*- ចាត់លេខាធិការឱ្យកត់ត្រាតួលេខនៃចំនួនដែលខុសគ្នានោះក្នុង ទ.១១០១ ប្រសិនបើភាពខុសគ្នានៅតែមាន។* |

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវបន្តចាត់ចែង* | *- ឱ្យសមាជិកទី២ ចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើទាំងអស់ ដោយប្រដាប់ចោះ ឬកន្ត្រៃ ដើម្បីធ្វើមោឃភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើ។*<br>*- ឱ្យអនុប្រធានដាក់សន្លឹកឆ្នោតមោឃភាព និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើទៅក្នុងស្បោងប្លាស្ទិកតែ១ រួចបិទឱ្យជិត។* |

## ២. រូបមន្តផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត

| | | | | |
|---|---|---|---|---|
| *ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត* | = | *ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង* | − | *ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ + ចំនួនសន្លឹកឆ្នោតខូច* |

## ៣. កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងការប្រើប្រាស់

| | |
|---|---|
| *ប្រធាន គ.ក.ប ត្រូវ* | *- ចាត់លេខាធិការឱ្យ៖*<br>*▪ កត់ត្រាជាមុននូវលេខសោឃ្លុំ ដែលនឹងត្រូវប្រើសម្រាប់ចាក់ឃ្លុំមាត់ស្បោង «ខ» ក្នុង ទ.១១០១។*<br>*▪ បោះត្រាសម្គាល់នៅជ្រុងខាងស្តាំប៉ែកខាងលើនៃ ទ.១១០១។*<br>*▪ ចុះហត្ថលេខាលើ ទ.១១០១ ទាំង ៣ ច្បាប់។*<br>*- ពិនិត្យ និងចុះហត្ថលេខាលើ ទ.១១០១ ទាំង ៣ច្បាប់ រួចឱ្យលេខាធិការបោះត្រាការិយាល័យបោះឆ្នោត។*<br>*- ដាក់បង្ហាញកំណត់ហេតុនេះចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ។*<br>*- អញ្ជើញភ្នាក់ងារគណបក្សនយោបាយ ឱ្យចូលរួមចុះហត្ថលេខាជាសាក្សី។ ការមិនព្រមចុះហត្ថលេខាពីភ្នាក់ងារគណបក្សនយោបាយមិនអាចចាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ។* |

ទ.១១០១ ចំនួន ៣ច្បាប់
- ១ច្បាប់ ដាក់ក្នុងស្រោមសំបុត្របោះពុម្ព ដែលមានកាខ្ទង់ថា«កំណត់ហេតុនៃការបោះឆ្នោត ផ្ញើជូន គ.ជ.ប»
- ១ច្បាប់ ដាក់ក្នុងស្រោមសំបុត្របោះពុម្ព ដែលមានកាខ្ទង់ថា «កំណត់ហេតុនៃការបោះឆ្នោត ផ្ញើជូន គធ.ខប»
- ១ច្បាប់ ដាក់ក្នុងស្រោមសំបុត្របោះពុម្ព ដែលមានកាខ្ទង់ថា«កំណត់ហេតុនៃការបោះឆ្នោត ផ្ញើជូន គឃ.សប»

**៤. ការរៀបចំដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រដោយឡែកពីគ្នា រួចដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព «ក» (មិនទាន់បិទត្រាសុវត្ថិភាព)**

ប្រធាន គ.ក.ប ត្រូវរៀបចំដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រដោយឡែកពីគ្នា រួចដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព «ក» ដែលមានបោះពុម្ពសម្គាល់ថា «ការិយាល័យបោះឆ្នោតលេខ...............» នូវ ៖

- ស្រោមសំបុត្រដាក់ ទ.១១០១ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត
- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតខូច» (បើមាន)
- ស្បោងប្លាស្ទិកដាក់ «សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ»
- ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់
- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត» (បើមាន)
- ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (បើមាន)។

**ចំណាំ៖**

ប្រធាន គ.ក.ប ត្រូវ ៖

- ពិនិត្យ និងផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ថា រាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារខាងលើ ត្រូវបានដាក់ក្នុងកញ្ចប់សុវត្ថិភាព «ក»។
- ធានាថា កញ្ចប់សុវត្ថិភាព «ក» នៅពេលនេះមិនត្រូវបិទភ្ជិតឡើយ ហើយនឹងត្រូវបិទភ្ជិតដោយការសុវត្ថិភាពបម្រុងស្រាប់ លុះណាតែ គ.ក.ប បានបញ្ចប់ការរាប់សន្លឹកឆ្នោត និងបានដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតទៅក្នុងកញ្ចប់សុវត្ថិភាព «ក» ពាក់ព័ន្ធ រួចរាល់សិន។
- ធានាថា កញ្ចប់សុវត្ថិភាព «ក» និងស្រោមសំបុត្រខាងលើ ត្រូវបានបំពេញលេខកូដការិយាល័យពាក់ព័ន្ធយ៉ាងត្រឹមត្រូវ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ ព្រមទាំងត្រូវរក្សាទុកឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ក្នុងពេលដែលការរាប់សន្លឹកឆ្នោតកំពុងដំណើរការ។

( មិនទាន់បិទការសុវត្ថិភាព )

**កញ្ចប់សុវត្ថិភាព «ក»**

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |

- ស្រោមសំបុត្រដាក់ ទ.១១០១ ផ្ញើជូន គ.ជ.ប
- ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត
- ស្រោមសំបុត្រដាក់ «សន្លឹកឆ្នោតខូច» (បើមាន)
- ស្បោងប្លាស្ទិកដាក់ «សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ»
- ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់
- ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត(បើមាន)
- ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (បើមាន)។

**៥. ការរៀបចំទុកដាក់សម្ភារ ឯកសារបោះឆ្នោត**

ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិកឱ្យ៖

- រៀបចំទុកដាក់សម្ភារ ឯកសារបោះឆ្នោតដែលនៅសល់ក្នុងកេសស័ង្កសី។
- វេចខ្ចប់ដបទឹកខ្មៅលុបមិនជ្រះដោយឡែក។
- រុះរើបន្ទប់សម្ងាត់ទាំង២ រួចច្រកទៅក្នុងការុងនីឡុងដែលបានប្រើពេលទទួល។
- រៀបចំទុកដាក់សម្ភារ ឯកសារបោះឆ្នោតខាងលើនោះឱ្យមានសុវត្ថិភាពនៅក្នុងការិយាល័យបោះឆ្នោត។

## VI. ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត

ការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោតនីមួយៗ ក្នុងឃុំ សង្កាត់ បន្ទាប់ពីបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួច នាល្ងាចថ្ងៃអាទិត្យទី២៩ ខែកក្កដា ឆ្នាំ២០១៨ លើកលែងតែការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបាន ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ហើយដែល គ.ជ.ប បានសម្រេចឱ្យ គឃ.សប ចាត់ចែងរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ នៅទីស្នាក់ការ គឃ.សប ឬនៅកន្លែងណាមួយដែលមានសុវត្ថិភាព។

ក្នុងករណីដែលការរាប់សន្លឹកឆ្នោត ត្រូវធ្វើនៅការិយាល័យបោះឆ្នោត ការិយាល័យបោះឆ្នោតនឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត ហើយ គ.ក.ប នឹងក្លាយទៅជា គ.ក.រ ។ ក្នុងករណីនេះ ប្រធាន គ.ក.ប នឹងក្លាយទៅជាប្រធាន គ.ក.រ។

កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅតែមួយកន្លែង សម្រាប់ការិយាល័យរាប់សន្លឹកឆ្នោតមួយ ។ ប្រសិនបើចាប់ផ្តើមហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយពុំត្រូវឈប់សម្រាកឡើយ។ ប្រធាន គ.ក.រ ត្រូវចាត់ចែងត្រៀមឱ្យមានភ្លើងបំភ្លឺនៅការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីបង្ការក្នុងករណីការរាប់សន្លឹកឆ្នោត ត្រូវអូសបន្លាយដល់ពេលយប់។

ប្រធាន គ.ក.រ ត្រូវចាត់ចែងរៀបចំតាមគំរូប្លង់បន្ទប់សម្រាប់ការរាប់សន្លឹកឆ្នោត និងមានវិធានការការពារសន្តិសុខក្នុងការិយាល័យរាប់សន្លឹកឆ្នោត។

**១. ការចាត់ចែងរៀបចំបន្ទប់សម្រាប់រាប់សន្លឹកឆ្នោត**

*ប្រធាន គ.ក.រ ត្រូវ*

- *រៀបតុធំ១ ឬតុតូចច្រើនផ្តុំគ្នា និងកៅអីចំនួន៤ សម្រាប់សមាជិក គ.ក.រ ដោយដាក់នៅចំកណ្តាលបន្ទប់ ដើម្បីអាចឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ដើរចុះឡើងជុំវិញតុ ក្នុងការសង្កេតតាមដានកិច្ចប្រតិបត្តិការនៃការរាប់សន្លឹកឆ្នោត។*
- *បិទផ្ទាំងក្រដាសធំភ្ជាប់នឹងជញ្ជាំង ឬលើក្តារខៀនសម្រាប់កត់ត្រាសំឡេងឆ្នោត។*
- *លើកហិបឆ្នោតដាក់នៅចំកណ្តាលតុ ព្រមទាំងយកកញ្ចប់សុវត្ថិភាព «ក» និង រាល់សម្ភារ ឯកសារ និងទម្រង់បែបបទចាំបាច់ត្រៀមសម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការនៃការរាប់សន្លឹកឆ្នោតដាក់នៅលើតុត្រង់កន្លែងខ្លួនអង្គុយ។*
- *ចាត់សមាជិកទី២ និងសមាជិកទី៣ ឱ្យបិទ Poster គំរូសន្លឹកឆ្នោតមិនបានការទាំង២ផ្ទាំង សហការគ្នាការពារមាត់ទ្វារ និងបង្អួចដែលត្រូវបើកចំហ កុំឱ្យមានអ្នកចេញ ចូល មើលថែរក្សាសុវត្ថិភាពសម្ភារ ឯកសារបោះឆ្នោតដែលមិនត្រូវប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត និងមើលថែរក្សាសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត។*

**២. ករណីជនណាព្យាយាមធ្វើសកម្មភាពដោយទុច្ចរិត ក្នុងគោលបំណងចង់ដឹងថា តើអ្នកបោះឆ្នោតណាម្នាក់បានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ**

*ប្រធាន គ.ក.រ ត្រូវ*

- *ព្រមានជននោះផ្ទាល់មាត់ ចំពោះការធ្វើសកម្មភាពលើកទី១។*
- *ចាត់ទុកថាជាការរំលោភលើគោលការណ៍សម្ងាត់នៃការបោះឆ្នោត ហើយជនដែលមានការពាក់ព័ន្ធត្រូវតែបណ្តេញចេញពីការិយាល័យរាប់សន្លឹកឆ្នោត និងត្រូវទទួលទោសតាម ច.ប.ត.រ ចំពោះការធ្វើសកម្មភាពជាលើកទី២។*
- *ចាត់លេខាធិការឱ្យកត់ត្រាទុកនូវហេតុការណ៍នេះ ក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត និងរាយការណ៍ជូន គឃ.សប។*

## គំរូប្លង់ការិយាល័យរាប់សន្លឹកឆ្នោត




**ចំណាំ**

- ក្នុងដំណើរការនៃការរាប់សន្លឹកឆ្នោត នៅការិយាល័យរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិត ល្មមដែលអាចសង្កេតមើលឃើញសកម្មភាពនៃការរាប់សន្លឹកឆ្នោត។
- ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលដំណើរការនៃការរាប់សន្លឹកឆ្នោត នៅតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ និងត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមាន (ទ.១១១៥) នៅមុនពេលចាប់ផ្តើមរាប់សន្លឹកឆ្នោត។
- ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចផ្លាស់ប្តូរភ្នាក់ងារបម្រុងរបស់ខ្លួន (បើមាន) ឱ្យបំពេញភារកិច្ចជំនួស និងត្រូវចូលរួមឱ្យបានចប់ចុងចប់ដើម។
- ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចថតយករូបភាពនៅការិយាល័យរាប់សន្លឹកឆ្នោតបាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ។

### ៣. សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ

ដើម្បីអនុវត្តកិច្ចប្រតិបត្តិការនៃការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គ.ក.រ ជាពិសេស ប្រធាន អនុប្រធាន គ.ក.រ ត្រូវយល់ដឹងយ៉ាងច្បាស់លាស់អំពីលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ។

#### ក. សន្លឹកឆ្នោតបានការ

- សន្លឹកឆ្នោតដែល គ.ក.ប ចែកឱ្យ។
- សន្លឹកឆ្នោតមានបោះត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនៅផ្នែកខាងខ្នង។
- សន្លឹកឆ្នោតមានគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ។

## ខ. សន្លឹកឆ្នោតមិនបានការ

សន្លឹកឆ្នោតមិនបានការដែលត្រូវបានចាត់ទុកជាមោឃៈ មាន ៥ប្រភេទ ដូចខាងក្រោម៖

### ខ.១ សន្លឹកឆ្នោតមិនផ្លូវការ៖

- សន្លឹកឆ្នោតមានខ្នាតតូចជាង ឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប។
- សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ជាង ឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប។
- សន្លឹកឆ្នោតមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប។
- សន្លឹកឆ្នោត ដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើន ដែលបានឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ។
- សន្លឹកឆ្នោត ដែលមានឈ្មោះគណបក្សនយោបាយលើសពីចំនួនគណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ។
- សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ។
- សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយ ដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោត ដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ និងដែលមិនបានផ្តល់ឱ្យដោយ គ.ក.ប ពាក់ព័ន្ធ។

### ខ.២ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូសដែរ តែគ.ក.រ ពុំអាចសន្និដ្ឋានបានថា បោះគាំទ្រឱ្យគណបក្សនយោបាយណាមួយ៖

- សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ)។
- សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយលើសពីមួយគណបក្ស។
- សន្លឹកឆ្នោតមានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយមួយដោយគូសហួសចូលទៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយមួយទៀត។
- សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើននៅក្រៅប្រអប់បួនជ្រុងទ្រវែងរបស់គណបក្សនយោបាយណាមួយ ទោះបីជាសន្លឹកឆ្នោតនោះមាន ឬគ្មានគំនូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយក៏ដោយ។

### ខ.៣ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេង ដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត៖

- សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លា ប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្ទៃខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត។

- សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះបីនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្ទៃកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត។
- សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗភ្ជាប់នឹងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬនៅលើផ្ទៃកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត។
- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ។
- សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត។

**ខ.៨ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូចមិនអាចយកជាបានការ**

- សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ។
- សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង។
- សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្ទៃកខាងមុខ ឬ/និងខាងខ្នងដែលមិនអាចមើលយល់នូវរូបសញ្ញា និងអក្សរដែលបានបោះពុម្ពនៅលើសន្លឹកឆ្នោត ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយណាមួយ។

**ខ.៨ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ**

- សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ
- សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

**ឧទាហរណ៍**

**ក. គំរូសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ព**



## ២. គំរូសន្លឹកឆ្នោតមិនបានការត្រូវបានចាត់ទុកជាមោឃៈ

### ២.១ សន្លឹកឆ្នោតដែលមិនមែនជាសន្លឹកឆ្នោតផ្លូវការ

សន្លឹកឆ្នោតទាំងឡាយណាដែលមិនបានផ្ដល់ឱ្យជាផ្លូវការដោយមន្ត្រីការិយាល័យបោះឆ្នោត ឬមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ក្លែងបន្លំ មិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ រួមមាន៖




១. សន្លឹកឆ្នោតមានខ្នាតតូចជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប




២. សន្លឹកឆ្នោតមានខ្នាតធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប




៣. សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង(ក្រាស់ជាង ឬស្តើងជាង)ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប




៤. សន្លឹកឆ្នោតមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប



៥. សន្លឹកឆ្នោតដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើនដែលបានឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ



៦. សន្លឹកឆ្នោតដែលមានឈ្មោះគណបក្សនយោបាយលើសពីចំនួនគណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ



៧. សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ



៨. សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយ ដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ និងដែលមិនបានផ្តល់ឱ្យដោយ គ.ក.ប ពាក់ព័ន្ធ

ខ.២ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូសដែរ តែ គ.ក.ស ពុំអាចសន្និដ្ឋានបានថា បោះឆ្នោតឱ្យគណបក្សនយោបាយ ណាមួយ




១. សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ)




២. សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយលើសពីមួយគណបក្ស




៣. សន្លឹកឆ្នោតមានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយមួយដោយគូសហួសចូលទៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយមួយទៀត




៤. សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើន នៅក្រៅប្រអប់បួនជ្រុងទ្រវែងរបស់គណបក្សនយោបាយណាមួយ ទោះបីជាសន្លឹកឆ្នោតនោះមាន ឬគ្មានគំនូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយក៏ដោយ

## ខ.៣ សន្លឹកឆ្នោតមានសញ្ញា ឬរូបភាពផ្សេង ដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត




១. សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លា ប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត




២. សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះបីនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត




៣. សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬ ក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗ ឆ្លាប់នឹងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត




៤. សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ




៩. សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត

## ខ.៤ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូចមិនអាចយកជាប្បានការ




១. សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ




២. សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង




៣. សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្ទៃកខាងមុខ ឬ/និង ខាងខ្នងដែលមិនអាចមើលឃើញនូវរូបសញ្ញា និងអក្សរដែលបានបោះពុម្ពនៅលើសន្លឹកឆ្នោត ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយណាមួយ

### ខ.៥ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការ



១. សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជា ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ



២.សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ

### ៨. កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត

ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ប្រធាន គ.ក.រ ត្រូវអង្គុយនៅចុងតុម្ខាង និង ឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខគាត់ ហើយអនុប្រធាន និងសមាជិក ទី១ ត្រូវអង្គុយនៅអមសងខាងតុទល់មុខគ្នា។ ស្ថិតនៅចំពោះមុខភ្នាក់ងារគណបក្ស នយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងបន្ទប់ ប្រធាន គ.ក.រ ត្រូវប្រកាស ចាប់ផ្ដើមកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ហើយត្រូវចាត់ចែងការងារ ដូចខាងក្រោម៖

**ក. ការរៀបចំសម្ភារ ឯកសារ**

ប្រធាន គ.ក.រ ត្រូវ៖

| | |
|---|---|
| *បម្រុងទុកនៅក្បែរខ្លួនគាត់* | *- កញ្ចប់សុវត្ថិភាព «ក»។<br>- ទ.១១១៥ សម្រាប់ស្រង់វត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត។<br>- ទ.១២០២ សម្រាប់ជូនភ្នាក់ងារគណបក្សនយោបាយ (ប្រសិនបើគាត់ស្នើសុំ)។<br>- ស្បោងប្លាស្ទិក សម្រាប់ដាក់សន្លឹកឆ្នោតបានការ និងស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ...។<br>- កៅស៊ូកង។* |
| *ឱ្យអនុប្រធាន* | *តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួន ១ច្បាប់។* |
| *ឱ្យលេខាធិការ* | *- ទ.១១០២ ចំនួនគ្រប់គ្រាន់ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។<br>- តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួន ១ច្បាប់។<br>- ស្រោមសំបុត្រដាក់ ទ.១១០១ ដែលត្រូវដកយកពីកញ្ចប់សុវត្ថិភាព «ក»និងប្រាប់គាត់ឱ្យបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយចម្លងនូវតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្ដែង ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ចំនួនសន្លឹកឆ្នោតខូច និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតដែលមានកត់ត្រានៅក្នុង ទ.១១០១។* |
| *ឱ្យសមាជិកទី១* | *ប៊ិកហ្វឺត ១ដើម និងផ្ទាំងក្រដាសធំ ១ផ្ទាំង សម្រាប់កត់ត្រាសំឡេងឆ្នោត។* |

## ខ. ការពិនិត្យហិបឆ្នោត នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

| ប្រធាន គ.ក.រ ត្រូវ | - ត្រួតពិនិត្យផ្ទៀងផ្ទាត់ឱ្យច្បាស់ថា សោឃ្លុំទាំង២ដែលចាក់ជាប់នឹងគម្របខាងក្រៅនៃហិបឆ្នោតស្ថិតក្នុងស្ថានភាពដើម។<br>- កាត់ផ្ដាច់សោឃ្លុំទាំងនេះដោយកន្ត្រៃ ឬកូនកាំបិត និងបើកគម្របខាងក្រៅចេញ។<br>- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់លេខសោឃ្លុំដែលចាក់ជាប់នឹងគន្លឹះខ្ទាស់បិទគម្របខាងក្នុងនៃហិបឆ្នោត និងក្រដាសស្ដើងដែលបិទពាសពីលើសន្ទះបិទភ្ជិតប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ដើម្បីបញ្ជាក់ថា គ្មានការរុះរើ។<br>- កាត់ផ្ដាច់សោឃ្លុំ និងហែកក្រដាសបិទពាសនេះចោល។<br>- បើកគម្របខាងក្នុងនៃហិបឆ្នោត។<br>- ចាក់សន្លឹកឆ្នោតឱ្យអស់ពីហិបឆ្នោត ដាក់នៅលើតុត្រង់ចន្លោះអនុប្រធាន និងសមាជិកទី១។<br>- ដាក់ហិបឆ្នោតទទេនៅក្បែរខ្លួន។ |
|---|---|

**ការចាក់សន្លឹកឆ្នោតចេញពីហិបឆ្នោត**




## គ. ការរាប់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត

ប្រធាន គ.ក.រ ត្រូវ៖

| ឱ្យសមាជិកទី១ | រើសយកវត្ថុមិនមែនជាសន្លឹកឆ្នោតដែលមិនស្ថិតនៅជាប់ជាមួយសន្លឹកឆ្នោត (បើមាន) ចេញពីគំនរសន្លឹកឆ្នោត រួចដាក់ក្នុងស្រោមសំបុត្រ១ បម្រុងស្រាប់។ |
|---|---|
| ឱ្យលេខាធិការ | កត់ត្រាវត្ថុដែលមិនមែនជាសន្លឹកឆ្នោតចូលក្នុង ទ.១១០២(បើមាន)។ |

| | | |
|---|---|---|
| ឱ្យអនុប្រធាន និងសមាជិកទី១ | ➔ | - លា និងតម្រៀបសន្លឹកឆ្នោតដែលទើបបានចាក់ចេញពីហិបឆ្នោត ដោយដាក់ផ្កាប់ចុះក្រោម។<br>- ដាក់សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នងក្នុង ១បាច់មាន ២៥សន្លឹក នៅពំនូកទី១។<br>- ដាក់សន្លឹកឆ្នោតដែលគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង (បើមាន) នៅពំនូកទី២។<br>- រាប់ចំនួនសន្លឹកឆ្នោតទាំង ២ពំនូក រួចរាយការណ៍ជូនប្រធានអំពីចំនួនសន្លឹកឆ្នោតសរុបដែលបានរាប់ឃើញ។<br>- ហុចសន្លឹកឆ្នោតពំនូកទី២ ដែលគ្មានបោះត្រាសម្ងាត់នៅខាងខ្នង(បើមាន) ជូនប្រធាន ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងស្តាំដៃគាត់។<br>- ហុចសន្លឹកឆ្នោតពំនូកទី១ ដែលខ្ទាស់ជាបាច់ក្នុង ១បាច់ ២៥សន្លឹក ជូនប្រធាន ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងឆ្វេងដៃគាត់។ |

**ឃ. ការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត**

- អនុវត្តតាមរូបមន្តៈ

| | | | | |
|---|---|---|---|---|
| ចំនួនសន្លឹកឆ្នោតចាក់ចេញពីហិបឆ្នោត និងបានរាប់ឃើញសរុប | = | ចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត | | |

ឬ

| | | | | |
|---|---|---|---|---|
| ចំនួនសន្លឹកឆ្នោតចាក់ចេញពីហិបឆ្នោត និងបានរាប់ឃើញសរុប | = | ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង | - | ចំនួនសន្លឹកឆ្នោតមិនបានប្រើ + ចំនួនសន្លឹកឆ្នោតខូច |

**ចំណាំ ៖**

ក្នុងការផ្ទៀងផ្ទាត់ៈ

- ប្រសិនបើស្មើគ្នា លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួននោះចូលក្នុង ទ.១១០២។
- ប្រសិនបើខុសគ្នា ប្រធានត្រូវផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតឡើងវិញជាលើកទី២ យ៉ាងហ្មត់ចត់។
- ប្រសិនបើនៅតែខុសគ្នាដដែល ប្រធាន គ.ក.រ ត្រូវៈ
    - ចាត់លេខាធិការឱ្យកត់ត្រាតួលេខដែលខុសគ្នានោះចូលក្នុង ទ.១១០២។
    - ប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតនោះ ដើម្បីឱ្យអ្នកទាំងនោះអាចពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនោះបាន។

### ង. ការកំណត់សុពលភាពសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការ

ប្រធាន គ.ក.រ ត្រូវយកសន្លឹកឆ្នោតម្តង ១សន្លឹកពីពំនូកទី១ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬមិនបានការ ព្រមទាំងត្រូវលើកបង្ហាញសន្លឹកឆ្នោតដែលបានកំណត់ហើយនោះ ដើម្បីឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍មើលឃើញច្បាស់។

➢ **ការកំណត់សន្លឹកឆ្នោតបានការដែលបានគូសគាំទ្រគណបក្សនយោបាយនីមួយៗ**

*ប្រធាន គ.ក.រ ត្រូវ*

- *កំណត់សន្លឹកឆ្នោតនោះ ជាសន្លឹកឆ្នោតបានការ។*
- *លើកបង្ហាញសន្លឹកឆ្នោតផ្នែកខាងមុខ ខាងខ្នងឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចមើលឃើញច្បាស់។*
- *ប្រកាសឱ្យឮៗ នូវឈ្មោះគណបក្សនយោបាយ ដែលសន្លឹកឆ្នោតនោះ ត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ។*
- *ដាក់សន្លឹកឆ្នោតបានការនោះទៅតាមពំនូកដោយឡែកៗ តាមគណបក្សនយោបាយពាក់ព័ន្ធនីមួយៗ។*
- *ចាត់អនុប្រធាន និងលេខាធិការឱ្យគូសពិន្ទុ១ សម្រាប់សន្លឹកឆ្នោត ១សន្លឹក ដែលគណបក្សនយោបាយពាក់ព័ន្ធបានទទួលនៅក្នុងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨)។*
- *ចាត់សមាជិកទី១ គូសពិន្ទុ១ ដោយប្រើប៊ិកហ្វឺតនៅលើផ្ទាំងក្រដាសធំដែលបិទភ្ជាប់នឹងជញ្ជាំង ឬលើក្តារខៀន។*
- *ប្រសិនបើមានការជំទាស់ពីភ្នាក់ងារគណបក្សនយោបាយក្នុងការកំណត់សុពលភាព ដាក់សន្លឹកឆ្នោតជំទាស់នោះទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ។*

**ការកំណត់សុពលភាពសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការ**



➢ **ការកំណត់សន្លឹកឆ្នោតមិនបានការ**

| | |
|---|---|
| *ប្រធាន គ.ក.រ ត្រូវ* | *- កំណត់ និងបញ្ជាក់ហេតុផលថា សន្លឹកឆ្នោតនោះជាសន្លឹកឆ្នោតមិនបានការ។*<br>*- ប្រកាសថាជាសន្លឹកឆ្នោតមិនបានការ។*<br>*- លើកបង្ហាញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យធ្វើការកត់សម្គាល់សន្លឹកឆ្នោតមិនបានការនោះ។*<br>*- ដាក់សន្លឹកឆ្នោតនោះទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ដែលស្ថិតនៅខាងស្តាំដៃគាត់។* |

**ច. ការកំណត់សុពលភាពចុងក្រោយនូវរាល់សន្លឹកឆ្នោតមិនបានការ**

ប្រធាន គ.ក.រ ត្រូវយកសន្លឹកឆ្នោតមិនបានការនៅខាងស្តាំដៃ ១សន្លឹកម្តងៗ រហូតដល់អស់សន្លឹកឆ្នោតពីពំនូកទី២ ដើម្បីពិនិត្យសុពលភាពជាចុងក្រោយ។ ប្រសិនបើពិនិត្យឃើញថា មិនច្បាស់លាស់ទៅលើសន្លឹកឆ្នោតណាមួយ ប្រធានត្រូវពិភាក្សាជាមួយសមាជិកទាំងអស់នៃ គ.ក.រ អំពីសុពលភាព និងការកំណត់ប្រភេទនៃសន្លឹកឆ្នោតនោះម្តងទៀត ដើម្បីកំណត់ចុងក្រោយថា ពិតជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ។

**ចំណាំ៖**

- ការកំណត់សុពលភាពសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ប្រធាន គ.ក.រ ត្រូវអនុវត្តដូចចំណុច «ង» ខាងលើនេះ។
- ប្រសិនបើភ្នាក់ងារគណបក្សនយោបាយណាម្នាក់មិនឯកភាពនឹងសេចក្តីសម្រេចរបស់ប្រធាន គ.ក.រ ក្នុងការកំណត់សន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការនោះ ភ្នាក់ងារគណបក្សនយោបាយនោះមានសិទ្ធិលើកការជំទាស់ និងស្នើសុំឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនៃការជំទាស់នោះចូលក្នុង ទ.១១០២។
- ប្រធាន គ.ក.រ ត្រូវចាត់លេខាធិការឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនោះចូល ក្នុង ទ.១១០២ ប្រសិនបើភ្នាក់ងារនោះយល់ព្រមចុះហត្ថលេខាលើកំណត់ហេតុនេះ។ ប្រសិនបើគាត់មិនព្រមចុះហត្ថលេខា ពុំបាច់កត់ត្រាក្នុងកំណត់ហេតុឡើយ។
- សេចក្តីសម្រេចរបស់ប្រធាន គ.ក.រ ត្រូវតែមានប្រសិទ្ធភាពក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយត្រូវប្រកាសបន្តដំណើរការរាប់សន្លឹកឆ្នោតតទៅទៀត។
- ប្រធាន គ.ក.រ ត្រូវជូន ទ.១២០២ ចំនួន ៣ច្បាប់ ដល់ភ្នាក់ងារគណបក្សនយោបាយនោះ (ប្រសិនបើគាត់ស្នើសុំ) ដើម្បីប្តឹងទៅ គឃ.សប។

**៥. ការបូកសរុបលទ្ធផល ការផ្ទៀងផ្ទាត់ និងការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោត**

**ក. ការបូកសរុបលទ្ធផល**

| | | |
|---|---|---|
| *ប្រធាន គ.ក.រ ត្រូវ* | *- ឱ្យអនុប្រធាននិងលេខាធិការបូកសរុបលើ ទ.១១០៨។*<br>*- ឱ្យសមាជិកទី១ បូកសរុបលើផ្ទាំងក្រដាសធំ។* | *- ចំនួនសន្លឹកឆ្នោតបានការតាមគណបក្សនយោបាយនីមួយៗ។*<br>*- ចំនួនសន្លឹកឆ្នោតបានការសរុប។*<br>*- ចំនួនសន្លឹកឆ្នោតមិនបានការសរុប។*<br>*- ផ្ទៀងផ្ទាត់តួលេខគ្នា។* |

| | |
|---|---|
| ប្រធាន គ.ក.រ ត្រូវ | - រាប់ចំនួនសន្លឹកឆ្នោតបានការតាមគណបក្សនយោបាយនីមួយៗ។<br>- រាប់ចំនួនសន្លឹកឆ្នោតមិនបានការទាំងអស់។<br>- ធ្វើការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតបានការដែលប្រធានរាប់ឃើញជាមួយតួលេខក្នុង ទ.១១០៨ របស់អនុប្រធាន និងលេខាធិការ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតរបស់សមាជិកទី១។<br>- បូកសរុបចំនួនសន្លឹកឆ្នោតបានការគ្រប់គណបក្សនយោបាយទាំងអស់។<br>- បូកសរុបបញ្ចូលគ្នាចំនួនសន្លឹកឆ្នោតបានការនិងចំនួនសន្លឹកឆ្នោតមិនបានការ។ |

ខ. រូបមន្តនៃការផ្ទៀងផ្ទាត់

| | | |
